00197680

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

C22/I/42

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

សំណុំរឿងព្រហ្មទណ្ឌ

លេខ:០០២/១៩-០៩-០៧-អវតក-កសចស(អបជ០៣)

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 25 / 06 / 2008
ម៉ោង (Time/Heure): 14:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

# របាយការណ៍ស្តីពីការត្រួតពិនិត្យ

I- នីតិវិធី

II- ការត្រួតពិនិត្យសំណុំរឿង

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 25 / 06 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

## I- នីតិវិធី

### ក- សេចក្តីផ្តើម

អនុលោមតាមវិធាន ៧៧-១០ នៃវិធានផ្ទៃក្នុងសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ប្រធានអង្គបុរេជំនុំជម្រះបានចាត់តាំងចៅក្រម **និយ ថុល** និង ចៅក្រម Katinka LAHUIS ឲ្យធ្វើរបាយការណ៍បង្ហាញលម្អិតនៃសេចក្តីសម្រេចក្នុងការចេញដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នរបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ដែលបានប្តឹងឧទ្ធរណ៍ និងបង្ហាញអង្គហេតុដែលពាក់ព័ន្ធនឹងសំណុំរឿង។

**ដែលក្នុងនោះ ជនត្រូវចោទ:**

ឈ្មោះ **អៀង សារី** ហៅ **វ៉ាន់** ភេទប្រុស កើតនៅថ្ងៃទី ២៤ ខែ តុលា ឆ្នាំ១៩២៥ នៅភូមិលឿង វ៉ា ឃុំលឿង វ៉ា ស្រុកត្រា វិញ ខេត្តត្រា វិញ កម្ពុជាក្រោម សញ្ជាតិខ្មែរ ទីលំនៅមុនពេលចាប់ខ្លួននៅផ្ទះលេខ៤៧B ផ្លូវលេខ២១ ក្រុម៣៦ មណ្ឌល៤ សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន ក្រុងភ្នំពេញ ប្រទេសកម្ពុជា ឪពុកឈ្មោះ **គឹម រៀម** (ស្លាប់) ម្តាយឈ្មោះ **ត្រាន់ ធិឡឺយ** (ស្លាប់)[1] ។

**អៀង សារី** មានសហមេធាវីការពារក្តីគឺ លោក **អាង ឧត្តម** និង លោក Michael KARNAVAS[2]។

---

[1] ទំព័រទី១ នៃដីកាបង្គាប់ឲ្យឃុំខ្លួន ចុះថ្ងៃទី ១៤ ខែវិច្ឆិកា ឆ្នាំ ២០០៧។

[2] លិខិតរបស់អង្គភាពគាំពារការពារក្តីដែលចាត់តាំងលោក **អាង ឧត្តម** ជាសហមេធាវីឲ្យ **អៀង សារី** ចុះថ្ងៃ ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៧
លិខិតរបស់អង្គភាពគាំពារការពារក្តីដែលចាត់តាំងលោក **អាង ឧត្តម** ជាសហមេធាវីឲ្យ **អៀង សារី** ចុះថ្ងៃ ០៩ ខែ មករា ឆ្នាំ ២០០៨
លិខិតចាត់តាំងសហមេធាវីឲ្យ **អៀង សារី** ជាអចិន្ត្រៃយ៍ ចុះថ្ងៃ ០៧ ខែ កុម្ភៈ ឆ្នាំ ២០០៨ និងសេចក្តីសម្រេចទទួលស្គាល់មេធាវីរបស់



ECCC PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE

**អៀង សារី** ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ ដែលជាបទល្មើសដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៥ មាត្រា ៦ មាត្រា ២៩ (ថ្មី) និងមាត្រា ៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤[3] ។

**- គោលបំណងរបស់របាយការណ៍**

របាយការណ៍នេះមានបង្ហាញលម្អិតនៃសេចក្តីសម្រេចដែលបានប្តឹងឧទ្ធរណ៍ និងបង្ហាញអង្គហេតុដែលមានបញ្ហានៅចំពោះមុខតុលាការនេះ។ គោលបំណងរបស់របាយការណ៍នេះ គឺដើម្បីជាជំនួយដល់អ្នកដែលមិនមែនជាភាគីនៃនីតិវិធីឲ្យបានយល់ដឹងអំពីរឿងហេតុនៅចំពោះមុខតុលាការ។

## ខ- ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា

នៅថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៧ សហព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានចេញដីកាបញ្ជូនរឿងឲ្យស៊ើបសួរទៅឲ្យសហចៅក្រមស៊ើបអង្កេត ដើម្បីបើកកិច្ចស៊ើបសួរ និងបានស្នើឲ្យចាប់និងឃុំខ្លួនជនសង្ស័យចំនួនប្រាំរូប ដែលក្នុងនោះមានឈ្មោះ **អៀង សារី** ហៅ **វ៉ាន់** ផងដែរ[4]។

សហព្រះរាជអាជ្ញាបានស្នើឲ្យឃុំខ្លួន **អៀង សារី** ជាបណ្តោះអាសន្ន ដោយហេតុផលថាមានមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា **អៀង សារី** បានប្រព្រឹត្តបទល្មើសខាងលើ ដូច្នេះការឃុំខ្លួនគឺជាវិធានការចាំបាច់ដើម្បីរារាំងកុំឲ្យមានការគាបសង្កត់ទៅលើសាក្សី ដើម្បីធានាអំពីវត្តមានរបស់ជននេះនៅក្នុងដំណើការនីតិវិធី ដើម្បីការពារសន្តិសុខផ្ទាល់ខ្លួនរបស់ជននេះ និងដើម្បីរក្សាសណ្តាប់ធ្នាប់សាធារណៈ[5]។

## គ- សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត

### ១) ស្ថានភាពអង្គហេតុ និងអង្គច្បាប់ដែលបានលើកឡើងក្នុងសេចក្តីសម្រេច

ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នបញ្ជាក់ថា ជនត្រូវចោទ "ត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភបំពានធ្ងន់ធ្ងរនៃអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា

---

សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃ ០៧ ខែ កុម្ភៈ ឆ្នាំ ២០០៨។

[3] ទំព័រទី១ នៃដីកាបង្គាប់ឲ្យឃុំខ្លួន ចុះថ្ងៃទី ១៤ ខែវិច្ឆិកា ឆ្នាំ ២០០៧។

[4] កថាខណ្ឌទី ១២៤ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ចុះថ្ងៃ ១៨ ខែ កក្កដា ឆ្នាំ ២០០៧។

[5] កថាខណ្ឌទី ១១៨ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ចុះថ្ងៃ ១៨ ខែ កក្កដា ឆ្នាំ ២០០៧។

ឆ្នាំ១៩៥៩ ដែលជាបទល្មើសដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៥ មាត្រា ៦ មាត្រា ២៩ (ថ្មី) និង មាត្រា ៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤។ បានឃើញការជជែកដេញដោលនៅថ្ងៃនេះ [...] សម្រេចឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទ **អៀង សារី** ចំនួនរយៈពេលអតិបរមា ១ ឆ្នាំ។ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧"[6]។

ជនត្រូវចោទ "បានជំទាស់នឹងអង្គហេតុដែលដាក់បន្ទុកលើខ្លួន ដោយប្រកាសថា 'មានការចោទប្រកាន់មួយចំនួនដែលខ្លួនមិនអាចទទួលយកបាន' ហើយស្នើសុំឱ្យបង្ហាញភស្តុតាងអំពីពិរុទ្ធភាពរបស់ខ្លួន។ ជនត្រូវចោទបន្ថែមថា '*ខ្ញុំចង់ដឹងការពិតអំពីកំឡុងពេលខ្មៅងងឹតនៅក្នុងប្រវត្តិសាស្ត្ររបស់យើង។ ខ្ញុំមិនដឹងថា ការពិតនៅឯណានោះទេ។ ខ្ញុំសប្បាយចិត្តណាស់ដែលតុលាការនេះត្រូវបានបង្កើតឡើង ពីព្រោះថានេះនឹងក្លាយជាឱកាសសម្រាប់ខ្ញុំក្នុងការស្វែងរកការពិត ក៏ដូចជាចូលរួមចំណែកនូវអ្វីដែលខ្ញុំដឹងផងដែរ*' ។

ជនត្រូវចោទស្នើសុំស្ថិតនៅក្រៅឃុំ ដោយភ័យខ្លាចស្លាប់នៅក្នុងមន្ទីរឃុំឃាំងមុនពេលដឹងការពិត និងលើកឡើងថា ប្រសិនបើគាត់ស្លាប់បាត់ទៅ ជនរងគ្រោះទីមួយគឺគ្រួសារខ្ញុំ តែជនរងគ្រោះទីពីរគឺតុលាការដែលនឹងបាត់សាក្សីមួយសំខាន់ ហើយនឹងត្រូវគេរិះគន់ជាមិនខាន។ ជនត្រូវចោទបានអះអាងថា ខ្លួនមិនដែលមានចេតនាលូកដៃចូលក្នុងនីតិវិធីឡើយ ដោយគូសបញ្ជាក់ថា ខ្លួនរស់នៅក្រៅឃុំជាច្រើនឆ្នាំមកហើយ និងបានដឹងអំពីលទ្ធភាពនៃការចោទប្រកាន់លើខ្លួនជាយូរណាស់មកហើយ ហើយខ្លួនក៏មានលទ្ធភាពអន្តរាគមន៍លើសាក្សីផងដែរ តែខ្លួនមិនបានធ្វើឡើយ។ ជនត្រូវចោទសូមអោយកត់សំគាល់ថា គាត់មានអាយុច្រើន ហើយមានជម្ងឺទៀត។ ជនត្រូវចោទទទូចថា គ្មានហានិភ័យនៃការរត់គេខ្លួនទេ ដោយប្រកាសថាត្រៀមខ្លួនជាស្រេចក្នុងការចូលខ្លួនក្នុងការកោះហៅ និងបានបញ្ជាក់ថា អាយុ និងស្ថានភាពសុខភាពរបស់ខ្លួនមិនអាចរត់គេចខ្លួនបានទេ។បើខ្លួនមានបំណងចង់រត់គេចនោះ ខ្លួននឹងរត់គេចតាំងពីយូរណាស់មកហើយ។ ពាក់ព័ន្ធនឹងហានិភ័យនៃការសងសឹក ចាប់តាំងពីការធ្វើសមាហរណកម្មជាមួយរដ្ឋាភិបាល ខ្លួនមិនដែលទទួលរងការគំរាមកំហែងណាមួយកើតឡើងទេ ទោះនៅទីក្រុងប៉ៃលិន ឬនៅក្រុងភ្នំពេញក៏ដោយ។ ផ្ទុយទៅវិញ ជនត្រូវចោទក៏បានរំលឹកថា ចាប់តាំងពីការកាត់ទោសដោយតុលាការប្រជាជនបដិវត្តនៅទីក្រុងភ្នំពេញ ថ្ងៃទី១៩ ខែសីហា ឆ្នាំ១៩៧៩ ខ្លួនបានទទួលការលើកលែងទោសដោយព្រះមហាក្សត្រកាលពីថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ១៩៩៦ មិនដែលមានចលាចលណាមួយកើតឡើងនោះទេ បន្ទាប់ពីការសម្រេចនេះ។ជនត្រូវចោទគូសបញ្ជាក់ថា ដោយសារតែខ្លួន ទើបកងទ័ពខ្មែរក្រហមបានធ្វើសមាហរណកម្មជាមួយរដ្ឋាភិបាល និងលើកឡើងថា ខ្លួនបានរួមវិភាគទានក្នុងការកសាងសន្តិភាពផងដែរ។ ជាទីបញ្ចប់ ជនត្រូវចោទស្នើសុំស្ថិតនៅក្រៅឃុំក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ"[7] ។

---

[6] ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧។

[7] កថាខណ្ឌទី៤ នៃដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧។

## ២) សំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេត

នៅក្នុងសំអាងហេតុសេចក្តីសម្រេច ជាដំបូង សហចៅក្រមស៊ើបអង្កេតពិចារណាទៅលើបញ្ហាផ្លូវច្បាប់ទាក់ទងនឹងសាលក្រមសម្រេចនៅឆ្នាំ១៩៧៩ ព្រមទាំងការអនុគ្រោះទោស និងការលើកលែងទោសនៅឆ្នាំ១៩៩៦។ ទាក់ទងនឹងសាលក្រមសម្រេចនៅឆ្នាំ១៩៧៩ សហចៅក្រមស៊ើបអង្កេតកត់សំគាល់ឃើញថា " [...] បច្ចុប្បន្ននេះ **អៀង សារី** មិនត្រូវបានចោទពីបទប្រល័យពូជសាសន៍ឡើយ"[8]។ សហចៅក្រមស៊ើបអង្កេតពិចារណាយល់ឃើញថា " យុត្តិសាស្ត្ររឹងមាំមួយរបស់តុលាការអន្តរជាតិបានកំណត់ថា ការប្រកាសពិរុទ្ធភាពត្រួតគ្នាចំពោះអង្គហេតុតែមួយអាចធ្វើឡើងទៅបាន នៅពេលបទល្មើសនីមួយៗមានធាតុផ្សំខុសគ្នាច្បាស់លាស់ ដែលបទល្មើសមួយទៀតគ្មាន។ [...] ដោយអនុវត្តតាមគោលការណ៍នេះ មិនមានអ្វីជាឧបសគ្គដល់ការចោទប្រកាន់ក្រោមការកំណត់បទល្មើសអន្តរជាតិផ្សេងពីបទល្មើសប្រល័យពូជសាសន៍លើ **អៀង សារី** ចំពោះអង្គហេតុដែលត្រូវបានកាត់សេចក្តីនៅឆ្នាំ១៩៧៩ ឡើយ"[9]។

អំពីវិសាលភាពនៃការអនុគ្រោះទោស និងការលើកលែងទោសឆ្នាំ១៩៩៦ សហចៅក្រមស៊ើបអង្កេតពិចារណាយល់ឃើញថា "ទាក់ទងនឹងអានុភាពនៃការអនុគ្រោះទោសរបស់ព្រះមហាក្សត្រ ជាការសំខាន់ដែលត្រូវគូសបញ្ជាក់ថា ការអនុគ្រោះទោសនេះកម្រិតត្រឹមការលុបចោលនូវទណ្ឌកម្ម និងការអនុវត្តទណ្ឌកម្មតែប៉ុណ្ណោះ។ ការអនុគ្រោះទោសនេះមិនប៉ះពាល់ដល់សាលក្រមផ្តន្ទាទោសដោយផ្ទាល់នោះទេ។ ហេតុដូច្នេះ ទោះបីការអនុគ្រោះទោសនេះអាចយកមកតតាំងបាននៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក៏ដោយ ក៏អនុគ្រោះទោសនេះមិនមានអានុភាពលើការចោទប្រកាន់នៅទីនេះឡើយ។មានតែបញ្ហាសាលក្រមខ្លួនឯងប៉ុណ្ណោះដែលជាបញ្ហាដែលបានលើករួចមកហើយក្នុងចំណុចខាងលើ។

ម្យ៉ាងវិញទៀត ការលើកលែងទោសនេះយោងយ៉ាងច្បាស់ដល់ច្បាប់ឆ្នាំ ១៩៩៤។ ប៉ុន្តែ ក្រៅពីការយោងមិនច្បាស់ដល់អំពើប្រល័យពូជសាសន៍ក្នុងបុព្វកថា ច្បាប់នេះយោងដល់តែបទល្មើសនៃច្បាប់ក្នុងស្រុកមួយចំនួនដែលត្រូវផ្តន្ទាទោសស្របតាមច្បាប់ជាតិជាធរមាន ក៏ដូចជាប្រភេទបទល្មើសប្រឆាំងនឹងសន្តិសុខជាតិ។ ដូច្នេះ ការលើកលែងទោសនេះមិនគ្របដណ្តប់លើបទល្មើសដែលជាសមត្ថកិច្ចរបស់អង្គជំនុំជម្រះវិសាមញ្ញឡើយ"[10]។

ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នបញ្ជាក់បន្ថែមទៀតអំពីសំអាងហេតុសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតក្នុងការចេញដីកាបង្គាប់ឲ្យឃុំខ្លួន។ សហចៅក្រមស៊ើបអង្កេតបានពិចារណាថា: "តាមរយៈឯកសារនិងចម្លើយសាក្សីជាច្រើនដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរដែលដាក់បន្ទុកលើ **អៀង សារី**

[8] កថាខណ្ឌទី៧ និង៨ នៃដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧។

[9] កថាខណ្ឌទី៩ នៃដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧។

[10] កថាខណ្ឌទី១២ និង១៣ នៃដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧។

អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

បង្កើតបានជាហេតុផលដែលអាចឲ្យជឿជាក់ថា **អៀង សារី** បានប្រព្រឹត្តបទល្មើសដូចដែលបានដាក់បន្ទុកមែន"[11]។

ម្យ៉ាងវិញទៀត សហចៅក្រមស៊ើបអង្កេតបានសម្រេចថា មានមូលហេតុគ្រប់គ្រាន់ក្នុងការចេញដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន។ មូលហេតុទាំងនេះមានដូចជា:

- រារាំងកុំឲ្យជនត្រូវចោទគាបសង្កត់លើសាក្សី ឬ ជនរងគ្រោះ
- ធានាអំពីវត្តមានរបស់ជនត្រូវចោទនៅក្នុងដំណើរការនីតិវិធី
- រក្សាសណ្ដាប់ធ្នាប់សាធារណៈ
- ការពារសន្តិសុខឲ្យជនត្រូវចោទ

ទាក់ទងនឹងបញ្ហាការដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ និងស្ថានភាពសុខភាពរបស់ជនត្រូវចោទ សេចក្ដីសម្រេចនោះបញ្ជាក់ថា: "ភាពធ្ងន់ធ្ងរជាពិសេសនៃបទល្មើសដែលចោទប្រកាន់ចំពោះ **អៀង សារី** នាំឲ្យមានហានិភ័យខាងលើកាន់តែច្បាស់ថែមទៀត និងមិនមានវិធានការត្រួតពិនិត្យតាមផ្លូវតុលាការណាមួយមានលក្ខណៈតឹងរ៉ឹងគ្រប់គ្រាន់អាចធានាថាបានបំពេញគ្រប់គ្រាន់នូវល័ក្ខខ័ណ្ឌតម្រូវខាងលើ អាស្រ័យហេតុនេះការឃុំខ្លួនគឺជាវិធានការតែមួយគត់ដើម្បីសម្រេចគោលដៅខាងលើនេះ។

មកដល់ពេលនេះ មិនមានសំអាងណាមួយដែលមេធាវីការពារក្ដីលើកឡើងដើម្បីឲ្យយើងជឿជាក់ថាស្ថានភាពសុខភាពរបស់ជនត្រូវចោទមានលក្ខណៈមិនសមស្របនឹងការឃុំខ្លួនឡើយ"[12]។

### ឃ- បណ្ដឹងឧទ្ធរណ៍ និងសារណារបស់ អៀង សារី ជំទាស់នឹងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន

#### ១) បណ្ដឹងឧទ្ធរណ៍

នៅថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០០៧ សហមេធាវីការពារក្ដីរបស់ **អៀង សារី** បានជូនដំណឹងពីការប្ដឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន ហើយនៅថ្ងៃទី ១៥ ខែ មករា ឆ្នាំ២០០៨ សហមេធាវីការពារក្ដីបានដាក់សារណាចូលមកអង្គបុរេជំនុំជម្រះ[13]។

នៅថ្ងៃទី ១៣ ខែមីនា ឆ្នាំ ២០០៨ សហមេធាវីការពារក្ដីបានដាក់ពាក្យស្នើសុំឲ្យអង្គបុរេជំនុំជម្រះពន្យារពេលការពិចារណាលើបណ្ដឹងឧទ្ធរណ៍ ហើយបង្គាប់ឲ្យសហចៅក្រមស៊ើបអង្កេតអនុញ្ញាតឲ្យជនត្រូវចោទបាន

---

[11] កថាខណ្ឌទី១៥ នៃដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧។

[12] កថាខណ្ឌទី១៩ ដល់ ២០ នៃដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧។

[13] សៀវភៅចុះបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០០៧ និងសារណាបណ្ដឹងឧទ្ធរណ៍របស់ **អៀង សារី** ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៨ ចំពោះដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧។

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

សម្រាកព្យាបាលនៅក្នុងមន្ទីរពេទ្យ។ នៅថ្ងៃទី ៣០ ខែមេសា ឆ្នាំ ២០០៨ អង្គបុរេជំនុំជម្រះបានសម្រេចថា បញ្ហានេះនឹងត្រូវដោះស្រាយជាមួយនឹងបញ្ហានៅក្នុងរឿងបណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន។

**២) សារណារបស់ អៀង សារី**

សហមេធាវីបានស្នើសុំឱ្យ:

- **កែប្រែលក្ខខណ្ឌឃុំខ្លួនបណ្តោះអាសន្នទៅជាលក្ខខណ្ឌឃុំខ្លួនក្នុងផ្ទះវិញ ក្រោមលក្ខខណ្ឌដែលអង្គបុរេជំនុំជម្រះយល់ឃើញថាជាការចាំបាច់។**

ដោយមានមូលហេតុដូចខាងក្រោម:

(ក) លក្ខខណ្ឌ និងទីកន្លែងឃុំខ្លួនបច្ចុប្បន្នបណ្តាលឱ្យសុខភាពរបស់ **អៀង សារី** ស្ថិតក្នុងហានិភ័យពិតប្រាកដដោយសារស្ថានភាពសុខភាពរបស់គាត់ ហេតុដូច្នេះ ទម្រង់នៃការឃុំខ្លួនសមស្របជាងនេះ គឺការឃុំខ្លួនក្នុងផ្ទះ [14] ហើយ

(ខ) ការឃុំខ្លួនក្នុងផ្ទះគឺជាទម្រង់នៃការត្រួតពិនិត្យតាមផ្លូវតុលាការ ហើយនៅក្នុងករណីនេះ វាជាលក្ខខណ្ឌគ្រប់គ្រាន់ដែលធានាចំពោះហានិភ័យណាមួយ[15]។

សហមេធាវីការពារក្តីលើកអំណះអំណាងថែមទៀតថា សហចៅក្រមស៊ើបអង្កេតបានរំលោភបំពានឆន្ទានុសិទ្ធិរបស់ខ្លួន ដោយធ្វើសេចក្តីសម្រេចរបស់ខ្លួនទៅលើវិចារណញ្ញាណអរូបី និងលើទស្សនៈយល់ឃើញជាទូទៅដោយមិនពឹងផ្អែកទៅលើអង្គហេតុទេ ហើយលើកឡើងទៀតថា ពុំមានមូលហេតុសម្រាប់ការឃុំខ្លួនបណ្តោះអាសន្នឡើយ[16]។

សហមេធាវីការពារក្តីបានលើកអំណះអំណាងថា ពួកគេនឹងមិនលើកឡើងពីបញ្ហាណាមួយទាក់ទងនឹង *ការគ្មានការកាត់ទោសពីរដងក្នុងបទល្មើសតែមួយ* ព្រមទាំងការអនុគ្រោះទោស និងការលើកលែងទោសរបស់ព្រះមហាក្សត្រដល់ជនត្រូវចោទឡើយ ដោយសូមរក្សាសិទ្ធិជំទាស់ក្នុងពេលសមស្របណាមួយ។

---

[14] កថាខណ្ឌទី ៥ និង៤៤ នៃសារណាបណ្តឹងឧទ្ធរណ៍របស់ **អៀង សារី** ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៨ ចំពោះដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧។

[15] ផ្នែក "ង" ជាពិសេស កថាខណ្ឌទី ៣៨ នៃសារណាបណ្តឹងឧទ្ធរណ៍របស់ **អៀង សារី** ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៨ ចំពោះដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ។

[16] កថាខណ្ឌទី ២១ , ២៦, ៣១ និង៣៦ នៃសារណាបណ្តឹងឧទ្ធរណ៍របស់ **អៀង សារី** ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៨ ប្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ។

## ខ- សេចក្តីសន្និដ្ឋានតប និងអំណះអំណាងរបស់សហព្រះរាជអាជ្ញា

### ១) សេចក្តីសន្និដ្ឋានតប

នៅថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០០៨ សហព្រះរាជអាជ្ញាបានដាក់សេចក្តីសន្និដ្ឋានតបទៅនឹងសារណាបណ្តឹងឧទ្ធរណ៍របស់ **អៀង សារី** [17]។

### ២) អំណះអំណាង

សហព្រះរាជអាជ្ញាលើកឡើងថា ការស្នើសុំរបស់ **អៀង សារី** ដែលសុំឱ្យឃុំខ្លួនក្នុងផ្ទះ គួរបដិសេធចោល ពីព្រោះ:

(ក) ល័ក្ខខ័ណ្ឌតាមវិធាន ៦៣-៣ (ខ) ត្រូវបានបំពេញ ហើយសហចៅក្រមស៊ើបអង្កេតបានអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនយ៉ាងសមស្របដែលបានយល់ឃើញថាការឃុំខ្លួនបណ្តោះអាសន្នគឺជាវិធានការចាំបាច់។ ហើយ

(ខ) ហេតុផលសុខភាពដែលគ្មានភស្តុតាងសំអាងដូចដែលបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍នោះ គឺពុំមានសំអាងគ្រប់គ្រាន់ ដែលនាំឱ្យមានការកែប្រែល័ក្ខខ័ណ្ឌនៃការឃុំខ្លួនបច្ចុប្បន្ន ទៅជាការឃុំខ្លួននៅក្នុងផ្ទះបានឡើយ[18]។

អំពីបញ្ហាយុត្តាធិការ សហព្រះរាជអាជ្ញាលើកឡើងថា សារណារបស់សហមេធាវីការពារក្តីគួរតែបញ្ចូលនូវអំណះអំណាងលើបញ្ហានេះ ដូចដែលបានលើកឡើងនៅក្នុងដីកាបង្គាប់ឱ្យឃុំខ្លួន ដែលជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍។

## គ -សារណារបស់អ្នកមិនមែនជាភាគីនៃរឿងក្តី (អ្នកមិនមែនជាភាគីនៃរឿងក្តីជាសាធារណជន ឬជាអង្គការដែលមិនពាក់ព័ន្ធក្នុងរឿងក្តី ប៉ុន្តែបានដាក់សារណាមកជួយតុលាការ)

នៅថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០០៨ តុលាការនេះបានអញ្ជើញសាធារណជន និងអង្គការ ឱ្យដាក់សារណាជាលាយលក្ខណ៍អក្សរដែលពាក់ព័ន្ធនឹងបញ្ហាណាមួយក្នុងករណីខាងលើ ក្នុងរយៈពេល១៥ថ្ងៃ[19]។ តុលាការសូមថ្លែងអំណរអរគុណដល់អ្នកដែលមិនមែនជាភាគីដែលបានដាក់សារណាចូលមក:

(១) អ្នកស្រី **អ៊ែន ហេនដល** និង

(២) លោក **ម៉ាដេវ ម៉ូហាន់** និងអ្នកស្រី **ទីនីថា រ៉ាម៉ានី ម៉ូហាន់**

---

[17] សេចក្តីសន្និដ្ឋានតបរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី២៩ ខែ មករា ឆ្នាំ ២០០៨ ដែលឆ្លើយតបទៅនឹងសារណាបណ្តឹងឧទ្ធរណ៍របស់ **អៀង សារី** ចំពោះដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ។

[18] កថាខណ្ឌទី ៦ នៃសេចក្តីសន្និដ្ឋានតបរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី២៩ ខែ មករា ឆ្នាំ ២០០៨ ដែលឆ្លើយតបទៅនឹងសារណាបណ្តឹងឧទ្ធរណ៍របស់ **អៀង សារី** ចំពោះដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧។

[19] សេចក្តីជូនដំណឹង ចុះថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០០៨។

សារណាទាំងនេះបានដោះស្រាយចំណុចគតិយុត្តសំខាន់ៗ ហើយមិនបានចង្អុលបង្ហាញផ្សេងពីរបាយការណ៍នេះឡើយ។ សហចៅក្រមរបាយការណ៍បញ្ជាក់ថា សារណានេះ ក៏ដូចជាសារណារបស់សហមេធាវីការពារក្តី និងសេចក្តីសន្និដ្ឋានតបរបស់សហព្រះរាជអាជ្ញានឹងត្រូវតុលាការយកមកពិចារណា។

**ឆ -ការស្នើសុំ និងសារណារបស់ អៀង សារី អំពីបញ្ហាយុត្តាធិការ**

**១) ការស្នើសុំ**

នៅថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០៨ អង្គបុរេជំនុំជម្រះបានអញ្ជើញសហមេធាវីការពារក្តីឱ្យដាក់សារណាឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងការពិចារណាលើបញ្ហាយុត្តាធិការ។ នៅថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០០៨ សហមេធាវីការពារក្តីបានដាក់សារណាឆ្លើយតប ដោយបញ្ជាក់ថា ពួកគេនៅតែយល់ឃើញថា បញ្ហាយុត្តាធិការគួរតែដោះស្រាយដាច់ដោយឡែកពីគ្នា ហើយបានស្នើសុំឱ្យអង្គបុរេជំនុំជម្រះយល់ឃើញថា ជនត្រូវចោទពុំទាន់បានបោះបង់សិទ្ធិជំទាស់ណាមួយទៅនឹងយុត្តាធិការនេះឡើយ ហើយជនត្រូវចោទនៅតែមានសិទ្ធិដាក់សារណាជំទាស់នឹងយុត្តាធិការនៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេតជានិច្ច។ លើសពីនេះ សហមេធាវីការពារក្តីបានស្នើសុំពន្យារពេលក្នុងការលើកឡើងពីបញ្ហាយុត្តាធិការ។ នៅថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០៨ ដោយបានបកស្រាយថា សំណើនេះជាសំណើសុំកំណត់ពេលដាក់សារណាលើបញ្ហាយុត្តាធិការ អង្គបុរេជំនុំជម្រះបានអនុញ្ញាតតាមសំណើចុងក្រោយនេះ ដោយពុំបានសម្រេចលើបញ្ហាទីមួយដែលសហមេធាវីការពារក្តីបានលើកឡើងនោះឡើយ។

**២) សារណា**

នៅថ្ងៃទី ០៧ ខែមេសា ឆ្នាំ ២០០៨ សហមេធាវីការពារក្តីបានដាក់សារណាជាភាសាអង់គ្លេស ដោយសហមេធាវីការពារក្តីលើកឡើងថា:

(ក) សវនាការជំនុំជម្រះលោក **អៀង សារី** ឆ្នាំ ១៩៧៩ រាំងមិនឱ្យ អ.វ.ត.ក ស៊ើបអង្កេត និងចោទប្រកាន់លោក **អៀង សារី** ពីបទឧក្រិដ្ឋណាមួយដែលមានកំណត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរឡើយ ស្របតាមគោលការណ៍*គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* ។

(ខ) ព្រះរាជទានការលើកលែងទោស និងការអនុគ្រោះទោសចំពោះលោក **អៀង សារី** នៅថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ ១៩៩៦ ជាការស្របច្បាប់ មានសុពលភាព និងអាចអនុវត្តបាន ហើយរាំងយុត្តាធិការរបស់ អ.វ.ត.ក ទៅលើលោក **អៀង សារី** ។

**៤ -សេចក្តីណែនាំ និងសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា**

PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE
E.C.C.C * C.E.T.C

**១) សេចក្តីណែនាំ**

នៅថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០៨ អង្គបុរេជំនុំជម្រះបានយល់ស្របតាមការស្នើសុំរបស់សហមេធាវីការពារក្តីក្នុងដាក់សារណាអំពីបញ្ហាយុត្តាធិការ។ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន អង្គបុរេជំនុំជម្រះបានណែនាំឲ្យសហព្រះរាជអាជ្ញាដាក់សេចក្តីសន្និដ្ឋានតបជាភាសាអង់គ្លេស និងភាសាខ្មែរ ប្រសិនបើមាន ក្នុងរយៈពេល១៥ ថ្ងៃ គិតចាប់ពីថ្ងៃជូនដំណឹងអំពីសារណារបស់សហមេធាវីការពារក្តី។ នៅថ្ងៃទី ០៧ ខែ មេសា ឆ្នាំ២០០៨ សហមេធាវីការពារក្តីបានដាក់សារណាជាភាសាអង់គ្លេស ហើយនៅថ្ងៃទី ៣០ ខែ មេសា ឆ្នាំ២០០៨ អត្ថបទបកប្រែជាភាសាខ្មែរត្រូវបានជូនដំណឹងដល់គូភាគី។

**២) សារណា**

នៅថ្ងៃទី ១៦ ខែឧសភា ឆ្នាំ ២០០៨ សហព្រះរាជអាជ្ញាបានដាក់សេចក្តីសន្និដ្ឋានតបទៅនឹងសារណារបស់ **អៀង សារី** អំពីបញ្ហាយុត្តាធិការ ដោយសហព្រះរាជអាជ្ញាលើកឡើងថា:

(ក) គោលការណ៍*គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* មិនអាចយកមកអនុវត្តបានទេនៅក្នុងករណីនេះ ដោយសារតុលាការប្រជាជនបដិវត្តពុំបានអនុលោមតាមបទដ្ឋាននៃការជំនុំជម្រះក្តីដោយត្រឹមត្រូវទេ

(ខ) ចំពោះការដាក់ទោសត្រួតគ្នាចំពោះបទល្មើសខុសគ្នាដែលកើតចេញពីអំពើតែមួយ ច្បាប់អន្តរជាតិពុំបានហាមឃាត់ឡើយ ក្នុងករណីដែលមានភាពមិនត្រឹមត្រូវណាមួយអាចត្រូវបានយកមកពិចារណា នៅពេលធ្វើការកាត់ទោស

(គ) ច្បាប់ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឲ្យនៅក្រៅច្បាប់ ពុំបានចែងពីបទល្មើសដែលបានចោទប្រកាន់នៅក្នុងសេចក្តីសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរឡើយ ដូច្នេះ ការលើកលែងទោសមិនអាចយកមកអនុវត្តបាននៅតុលាការនេះឡើយ ហើយ

(ឃ) វិសាលភាពនៃការអនុគ្រោះទោសនេះ វាមានកម្រិតចំពោះការមិនអនុវត្តទោសប្រហារជីវិត និងការរឹបអូសទ្រព្យសម្បត្តិ ហើយវាមិនអាចរារាំងដល់ការស៊ើបអង្កេត និងការចោទប្រកាន់ជនត្រូវចោទក្នុងពេលអនាគតបានឡើយ។

**ឈ -សេចក្តីណែនាំ និងសារណារបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**១) សេចក្តីណែនាំ**

នៅថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៨ អង្គបុរេជំនុំជម្រះបានណែនាំឲ្យមេធាវីដើមបណ្តឹងរដ្ឋប្បវេណីដាក់សារណាតបតែមួយគត់ មិនឲ្យលើសពី ១៥ ទំព័រ ជាភាសាអង់គ្លេស ឬ ៣០ ទំព័រ ជាភាសាខ្មែរ ប្រសិនបើមាន ក្នុងរយៈពេល១៥ ថ្ងៃ។ សារណារួមគ្នាមិនឲ្យលើសពី ៤៥ ទំព័រ ជាភាសាអង់គ្លេស ឬ ៩០ ទំព័រ ជាភាសាខ្មែរ។

**២) សារណា**

នៅថ្ងៃទី ២០ ខែឧសភា ឆ្នាំ ២០០៨ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានដាក់សារណារួមគ្នាឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់ **អៀង សារី** ចំពោះដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ដោយមេធាវីដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងថា:

(ក) គោលការណ៍ *គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* មិនអាចយកមកអនុវត្តបាន [...] ដោយសារនីតិវិធីពុំបានប្រព្រឹត្តដោយ (ក) ឯករាជ្យ (ខ) អនាគតិ (គ) និងពុំបានស្របតាមបទដ្ឋានអន្តរជាតិ

(ខ) [...] ការអនុគ្រោះទោសនេះរំលោភលើបទដ្ឋានអន្តរជាតិ ដូច្នេះហើយវាក៏មិនមានលក្ខណៈស្របច្បាប់ និងចងកាតព្វកិច្ចនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញដែរ ។ ហើយ

(គ) ឆន្ទានុសិទ្ធិរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតត្រូវបានអនុវត្តយ៉ាងត្រឹមត្រូវ ហើយបង្ហាញនូវហេតុផលសមស្រប និងរឹងមាំ។

- **អនុសាសន៍បន្ថែម**

សារណាជាសាធារណៈទាំងអស់របស់ភាគី រួមទាំងសារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី ត្រូវបានផ្សាយតាមគេហទំព័ររបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

## II- ការត្រួតពិនិត្យសំណុំរឿង

### ក- ចំណុចច្បាប់

#### ១) បញ្ហាយុត្តាធិការជាផ្នែកមួយនៃបណ្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន

សហមេធាវីការពារក្តីលើកឡើងក្នុងសារណាបណ្តឹងឧទ្ធរណ៍របស់ខ្លួនថា "លោក **អៀង សារី** នឹងមិនលើកឡើងនូវបញ្ហាណាមួយដែលជាផ្នែកមួយនៃបណ្តឹងឧទ្ធរណ៍របស់ខ្លួនចំពោះដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នទាក់ទងនឹងគោលការណ៍ *គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* និងព្រះរាជក្រឹត្យអនុគ្រោះទោស និងលើកលែងទោសឲ្យលោក **អៀង សារី** ឡើយ ដោយរក្សាសិទ្ធិលើកជំទាស់ទាំងស្រុងចំពោះការវិភាគ និងការយល់ឃើញផ្នែកច្បាប់ណាមួយរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតលើបញ្ហាទាំងនេះ នៅពេលសមស្របណាមួយ។ ការសម្រេចរបស់លោក **អៀង សារី** ក្នុងការមិនលើកឡើងដោយជាក់លាក់នូវបញ្ហាទាក់ទងនឹងគោលការណ៍ *គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* និងព្រះរាជក្រឹត្យអនុគ្រោះទោស និងលើកលែងទោស <u>**មិនគួរ**</u> យល់ឃើញថាជាការបោះបង់សិទ្ធិនេះចោលឡើយ"[20]។

ជាការឆ្លើយតប សហព្រះរាជអាជ្ញាលើកឡើងថា "វិធានផ្ទៃក្នុងមិនមានចែងអំពីការបោះបង់សិទ្ធិបែបនេះឡើយ។ វិធាន ៧៥-១ ចែងអនុញ្ញាតឲ្យធ្វើបណ្តឹងឧទ្ធរណ៍ចំពោះដីការបស់សហចៅក្រមស៊ើបអង្កេតក្នុងរយៈពេល ៣០ ថ្ងៃ។ ដូច្នេះ ក្នុងករណីពុំបានប្តឹងឧទ្ធរណ៍ ឬពុំបានលើកឡើងបញ្ហាជាក់លាក់ណាមួយនៅក្នុងសេចក្តីសម្រេចដែលបានប្តឹងឧទ្ធរណ៍ទេនោះ គួរចាត់ទុកថាជាការបោះបង់ចោល។

[...] ករណីដែលសហចៅក្រមស៊ើបអង្កេតពុំបានជូនដំណឹងជាផ្លូវការដល់ភាគីថា បញ្ហានេះនឹងត្រូវលើកឡើងនៅក្នុងសវនាការតទល់គ្នានោះទេ ជាលទ្ធផល **អៀង សារី** មិនអាចទាមទារថា ខ្លួនអាចជ្រើសរើសផ្នែកណាមួយនៃដីកាបង្គាប់ឲ្យឃុំខ្លួនដែលខ្លួនចង់ប្តឹងឧទ្ធរណ៍នាពេលនេះ និងផ្នែកណាមួយដែលខ្លួននឹងត្រូវជ្រើសរើសក្នុងការលើកឡើងនៅពេលក្រោយស្រេចតែចិត្តបានឡើយ។ បន្ទាប់ពីចេញដីកាសម្រេចរួច **អៀង សារី** និងមេធាវីរបស់ខ្លួនមានរយៈពេល៣០ ថ្ងៃ ដើម្បីប្តឹងឧទ្ធរណ៍។ ជាលទ្ធផល ប្រសិនបើជនត្រូវចោទកើតទុក្ខមិនសុខចិត្តនឹងផ្នែកណាមួយនៃដីកាបង្គាប់ឲ្យឃុំខ្លួន ខ្លួនត្រូវតែលើកឡើងចំណុចនោះនាពេលនោះភ្លាម បើមិនដូច្នេះទេ ខ្លួននឹងបាត់បង់សិទ្ធិនេះជាមិនខាន។

[20] កថាខណ្ឌទី៦ នៃសារណាបណ្តឹងឧទ្ធរណ៍របស់ **អៀង សារី** ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២00៨ ចំពោះដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២00៧។

តាមលក្ខណៈធម្មតា និងរចនាសម្ព័ន្ធរបស់ខ្លួន ស្ថាប័នតុលាការរបស់ អ.វ.ត.ក ព្រមទាំងនីតិវិធីនៅទីនេះ គឺមានលក្ខណៈស៊ើបអង្កេត មិនមែនអាស្រ័យលើភស្តុតាងរបស់គូភាគីនោះទេ។ ខណៈពេលដែលគូភាគីអាច លើកឡើងនូវបញ្ហា និងបណ្តាលឲ្យមានសេចក្តីសម្រេចពីតុលាការ ស្ថាប័នតុលាការមានស្វ័យភាពក្នុងការដោះស្រាយបញ្ហាណាមួយដែលពាក់ព័ន្ធនឹងសំណុំរឿងនៅពេលសមស្របណាមួយ។

[...]

ចំពោះបញ្ហាដែលជាបញ្ហាយុត្តាធិការតុលាការណាក៏ដោយ គួរតែកាត់សេចក្តីឲ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន។បញ្ហាទាំង នេះមានសក្តានុពលមោឃភាពការស៊ើបសួរ និងការចោទប្រកាន់។ វានឹងក្លាយជាការប្រើប្រាស់មិនសមស្របនូវពេលវេលានិងធនធានមានកំណត់របស់តុលាការនេះក្នុងការបន្តការស៊ើបអង្កេតទៅលើចុងចោទ ប្រសិនបើក្រោយមកត្រូវរាំងស្ទះទៅវិញដោយសារតែបញ្ហាដែលអាចកាត់សេចក្តីពីមុនបាននោះ។ វិធានផ្ទៃក្នុងកំណត់ច្បាស់ថា ការជំទាស់ទៅនឹងយុត្តាធិការនឹងអាចកាត់សេចក្តីបាននៅដំណាក់កាលមុនអង្គសេចក្តីហើយផ្តល់សមត្ថកិច្ចឲ្យអង្គបុរេជំនុំជម្រះធ្វើការសម្រេចសេចក្តីលើបណ្តឹងឧទ្ធរណ៍ចំពោះសេចក្តីសម្រេចដែលបញ្ជាក់ពីយុត្តាធិការរបស់ អ.វ.ត.ក។ អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះគួរតែសម្រេចសេចក្តីលើបញ្ហាទាំងនេះនៅក្នុងរឿងបណ្តឹងឧទ្ធរណ៍នេះ។ សូមស្នើថា គូភាគីគួរទទួលបាននូវឱកាសដាក់សារណាជាលាយលក្ខណ៍អក្សរលើបញ្ហាទាំងនេះ មុនសវនាការផ្ទាល់មាត់”[21]។

នៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ ២០០៨ តាមការអញ្ជើញរបស់អង្គបុរេជំនុំជម្រះ[22] សហមេធាវីការពារក្តីបានឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានស្តីអំពីបញ្ហាយុត្តាធិការនេះ ដោយលើកឡើងថា “បញ្ហាទាំងនេះ សហចៅក្រមស៊ើបអង្កេតបានលើកឡើងភ្លាមៗ ដោយហេតុថាបញ្ហាទាំងនេះវាស្ថិតនៅក្រៅវិសាលភាពនៃដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នចុះថ្ងៃទី ១៤ ខែវិច្ឆិកា ឆ្នាំ២០០៧។ ដូច្នេះ ការសម្រេចណាមួយដោយការិយាល័យសហចៅក្រមស៊ើបអង្កេតលើបញ្ហាទាំងនេះ គឺ ១)ហួសពីដែនសមត្ថកិច្ច ២) មិនមានការតម្រូវឲ្យការិយាល័យសហចៅក្រមស៊ើបអង្កេតចេញសេចក្តីសម្រេចរបស់ខ្លួនលើបញ្ហាដែលកំពុងកើតឡើងនោះទេ (ពោលគឺបញ្ហាការឃុំខ្លួនបណ្តោះអាសន្ន) និង ៣) មិនអាច និងមិនគួរអង្គបុរេជំនុំជម្រះចាត់ទុកថាជាការបានបោះបង់នោះទេ នៅពេលដែលសហមេធាវីការពារក្តីមិនបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍របស់ខ្លួនចំពោះការឃុំខ្លួនបណ្តោះអាសន្ននោះ”[23]។

---

[21] កថាខណ្ឌទី១៤,១៥, ១៦ និង១៨ នៃសេចក្តីសន្និដ្ឋានតបរបស់សហព្រះរាជអាជ្ញា ដែលឆ្លើយតបទៅនឹងសារណាបណ្តឹងឧទ្ធរណ៍របស់ **អៀង សារី** ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៨ ចំពោះដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ។

[22] លិខិតអញ្ជើញឲ្យឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានតបរបស់សហព្រះរាជអាជ្ញាអំពីបញ្ហា *ការគ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* ការអនុគ្រោះទោស និងការលើកលែងទោស ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០៨ ។

[23] កថាខណ្ឌទី២ នៃសំណើសុំជាបន្ទាន់នូវពេលវេលាសមស្របក្នុងការដាក់សារណាជំទាស់នឹងបញ្ហាយុត្តាធិការ និងឆ្លើយតបនឹងការអញ្ជើញរបស់អង្គបុរេជំនុំជម្រះ ទៅនឹងសេចក្តីសន្និដ្ឋានរបស់ការិយាល័យសហដែលឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហមេធាវី

នៅក្នុងរឿងនេះ សហមេធាវីការពារក្តីលើកឡើងថា "លក្ខណៈវិនិច្ឆ័យសម្រាប់ធ្វើការសម្រេចសេចក្តីលើបញ្ហាការឃុំខ្លួនបណ្តោះអាសន្ន មានចែងយ៉ាងច្បាស់នៅក្នុងវិធាន ៦៣-៣ នៃវិធានផ្ទៃក្នុង [...]។

[...] <u>**គ្មានផ្នែកណាមួយនៃវិធាននេះចែងថា ការិយាល័យសហចៅក្រមស៊ើបអង្កេតត្រូវសម្រេចផងដែរទៅលើបញ្ហាចុងក្រោយនៃយុត្តាធិការផ្ទាល់ខ្លួនលើជនត្រូវចោទឡើយ**</u>។

ម្យ៉ាងវិញទៀត ទោះបីជា គោលការណ៍ *គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* និងព្រះរាជក្រឹត្យអនុគ្រោះទោស និងលើកលែងទោសលោក **អៀង សារី** ឆ្នាំ ១៩៩៦ មិនត្រូវបានគេចាត់ទុកថា *ហួសពីដែនសមត្ថកិច្ច* ក៏ដោយ ក៏វាពុំអាចបង្កើតជាបញ្ហាអាចប្តឹងឧទ្ធរណ៍បានដែរ។ នៅក្នុងបរិបទនៃពាក្យថា ឆន្ទានុសិទ្ធិ ជំនួសពាក្យថា បណ្តឹងឧទ្ធរណ៍ដោយស្វ័យប្រវត្តិ យុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិផ្តល់ប្រយោជន៍នៅក្នុងរឿងក្តីនេះ។ ដើម្បីទទួលបានការអនុញ្ញាតឲ្យប្តឹងឧទ្ធរណ៍ ភាគីដែលសុំប្តឹងឧទ្ធរណ៍ត្រូវតែកំណត់អត្តសញ្ញាណបញ្ហាណាមួយពាក់ព័ន្ធនឹងសេចក្តីសម្រេចដែលអាចប្តឹងឧទ្ធរណ៍បាន ពោលគឺ 'បញ្ហាណាមួយដែលបង្កើតឡើងដោយកម្មវត្ថុមួយដែលដំណោះស្រាយរបស់វាមានសារៈសំខាន់ក្នុងការកំណត់លើបញ្ហាដែលកើតឡើងនៅក្នុងរឿងក្តីនៅតុលាការដែលកំពុងស្ថិតក្រោមការត្រួតពិនិត្យ'។

ជាធម្មតា ផ្នែកណាមួយនៃសេចក្តីសម្រេចនឹងប្តឹងឧទ្ធរណ៍បាន តែក្នុងករណីបញ្ហានោះត្រូវដោះស្រាយដោយចៅក្រម ឬដោយអង្គជំនុំជម្រះ ដើម្បីធ្វើការសម្រេចសេចក្តីចុងក្រោយលើបញ្ហាដែលកំពុងកើតឡើងនោះ។ នៅក្នុងរឿងក្តីនេះ បញ្ហាដែលកំពុងកើតឡើង គឺជាការឃុំខ្លួនបណ្តោះអាសន្នលើលោក **អៀង សារី** តាមវិធាន ៦៣។ បញ្ហាទាក់ទងនឹង*ការគ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* និងព្រះរាជក្រឹត្យអនុគ្រោះទោស និងលើកលែងទោសលោក **អៀង សារី** ឆ្នាំ ១៩៩៦ ពុំចាំបាច់ត្រូវដោះស្រាយដើម្បីធ្វើការសម្រេចសេចក្តីបែបនេះឡើយ។ ហេតុដូច្នេះ សេចក្តីសម្រេចពុំបានបង្កើតឲ្យមានជាបញ្ហាអាចប្តឹងឧទ្ធរណ៍បាន ហើយសហមេធាវីការពារក្តីក៏មិនអាចប្តឹងឧទ្ធរណ៍បានដែរ។ ដើម្បីឲ្យការិយាល័យសហព្រះរាជអាជ្ញាបញ្ជាក់ថា ការមិនបានប្តឹងឧទ្ធរណ៍របស់សហមេធាវីការពារក្តីជាការបោះបង់សិទ្ធិប្តឹងឧទ្ធរណ៍នោះ ជាធម្មតា វាមិនអាចរក្សាបាន ហើយដោយគ្មានអង្គសេចក្តីទៀតផង"[24]។

សហមេធាវីការពារក្តីលើកឡើងថែមទៀតថា " មុនសវនាការតទល់គ្នា សហមេធាវីការពារក្តីរបស់លោក **អៀង សារី** មិនបានទទួលដំណឹងជាមុនទេ ហើយក្រោយពីសវនាការតទល់គ្នា សហមេធាវីការពារក្តីរបស់លោក

ការពារក្តីចំពោះការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ ២០០៨។

[24] កថាខណ្ឌទី៦ ដល់៩ នៃសំណើសុំជាបន្ទាន់នូវពេលវេលាសមស្របក្នុងការដាក់សារណាជំទាស់នឹងបញ្ហាយុត្តាធិការ និង[illegible] ការអញ្ជើញរបស់អង្គបុរេជំនុំជម្រះ ទៅនឹងសេចក្តីសន្និដ្ឋានរបស់ការិយាល័យសហព្រះរាជអាជ្ញាដែលឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហមេធាការពារក្តីចំពោះការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ ២០០៨។

**អៀង សារី** ក៏មិនបានគេអញ្ជើញឱ្យទៅធ្វើអំណះអំណាងអំពីបញ្ហាទាំងនេះមុននឹងចេញដីកាបង្គាប់ឱ្យឃុំខ្លួនដែរ។ តាមរយៈការសម្រេចសេចក្ដីលើបញ្ហាដែលសហមេធាវីការពារក្ដីពុំអាចធ្វើអំណះអំណាងបាន ច្បាស់ណាស់ថាការិយាល័យសហចៅក្រមស៊ើបអង្កេតបានរំលោភលើសិទ្ធិរបស់ **អៀង សារី** ក្នុងការលើកឡើងនូវអំណះអំណាង ហើយបានបញ្ចៀសសិទ្ធិពិតប្រាកដរបស់គាត់ក្នុងការជំទាស់នឹងយុត្តាធិការ។

[...]

មធ្យោបាយត្រឹមត្រូវ និងយុត្តិធម៌ក្នុងការសងជម្ងឺចិត្តដល់លោក **អៀង សារី** ចំពោះការរំលោភលើសិទ្ធិជាមូលដ្ឋាន (សិទ្ធិមនុស្ស) របស់គាត់ក្នុងការទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌លើបញ្ហាទាំងនេះ គឺមានតែអង្គបុរេជម្រះសម្រេចមិនពិចារណាលើផ្នែកទាំងឡាយនៃដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នដែលដោះស្រាយបញ្ហា *គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* និងព្រះរាជក្រឹត្យអនុគ្រោះទោស និងលើកលែងទោសលោក **អៀង សារី** ឆ្នាំ១៩៩៦ ហើយ លុបចេញដោយប្រតិសកម្មចេញពីកំណត់ហេតុរបស់អង្គបុរេជំនុំជម្រះសម្រាប់គោលបំណងនៃបណ្ដឹងឧទ្ធរណ៍នេះ។ មានតែករណីនេះប៉ុណ្ណោះទេទើបអាចការពារសិទ្ធិរបស់លោក **អៀង សារី** បានគ្រប់គ្រាន់ក្នុងការលើកឡើងនូវអំណះអំណាងលើបញ្ហាទាំងនេះ ក្នុងពេលសមស្រប"[25]។

ទាក់ទងនឹងការបោះបង់សិទ្ធិនេះ សហមេធាវីការពារក្ដីលើកឡើងថា "ដោយសារសារៈសំខាន់ជាសារវ័ន្តនៃបញ្ហាដែលកំពុងកើតឡើង និងដោយសារការរកឃើញពីកង្វះខាតយុត្តាធិការដែលនឹងត្រូវលើកយកមកកាត់សេចក្ដីការជំទាស់នឹងយុត្តាធិការពុំអាចចាត់ទុកបានយ៉ាងងាយថាជាការបោះបង់ដោយធ្វេសប្រហែសនោះទេ ពិសេសនៅពេលបានជូនដំណឹងដល់អាជ្ញាធរតុលាការដែលពាក់ព័ន្ធ (អង្គបុរេជំនុំជម្រះ) ឱ្យបានដឹងថា បញ្ហាមិនកំពុងត្រូវបានគេបោះបង់នោះទេ ហើយវានឹងត្រូវលើកយកមកពិភាក្សាក្នុងពេលវេលាត្រឹមត្រូវទៀតផង"[26]។

ចុងបញ្ចប់ សហមេធាវីការពារក្ដីលើកឡើងថា " ការិយាល័យសហព្រះរាជអាជ្ញាលើកឡើងក្នុងសេចក្ដីសន្និដ្ឋានរបស់ខ្លួនថា ដោយសារតែបញ្ហា *គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* និងព្រះរាជក្រឹត្យអនុគ្រោះទោស និងលើកលែងទោសលោក **អៀង សារី** ឆ្នាំ១៩៩៦ គឺជាបញ្ហាយុត្តាធិការ ដូច្នេះបញ្ហាទាំងនេះគួរតែត្រូវបានដោះស្រាយ'ឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន'។ [...] សហមេធាវីការពារក្ដីពុំបានជំទាស់នឹងការលើកឡើងពីគោលការណ៍ទាំងនេះទេ ប៉ុន្តែអះអាងថា ការលើកឡើងទាំងនេះ**<u>មិនផ្ដល់ការគាំទ្រណាមួយដល់</u>**

[25] កថាខណ្ឌទី១០ និង១៣ នៃសំណើសុំជាបន្ទាន់នូវពេលវេលាសមស្របក្នុងការដាក់សារណាជំទាស់នឹងបញ្ហាយុត្តាធិការ និងឆ្លើយតបតាមការអញ្ជើញរបស់អង្គបុរេជំនុំជម្រះ ទៅនឹងសេចក្ដីសន្និដ្ឋានរបស់ការិយាល័យសហដែលឆ្លើយតបទៅនឹងបណ្ដឹងឧទ្ធរណ៍របស់សហមេធាវីការពារក្ដីចំពោះការឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ ២០០៨។

[26] កថាខណ្ឌទី១៤ នៃសំណើសុំជាបន្ទាន់នូវពេលវេលាសមស្របក្នុងការដាក់សារណាជំទាស់នឹងបញ្ហាយុត្តាធិការ និងឆ្លើយតបតាមការអញ្ជើញរបស់អង្គបុរេជំនុំជម្រះ ទៅនឹងសេចក្ដីសន្និដ្ឋានរបស់ការិយាល័យសហដែលឆ្លើយតបទៅនឹងបណ្ដឹងឧទ្ធរណ៍របស់សហមេធាវីការពារក្ដីចំពោះការឃុំខ្លួនបណ្ដោះអាសន្នចុះថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ ២០០៨។

<u>សេចក្តីសន្និដ្ឋានរបស់ការិយាល័យសហព្រះរាជអាជ្ញា</u> ដែលថា ជាលទ្ធផល បញ្ហាទាំងនេះគួរត្រូវបានលើកយកមកពិភាក្សានៅក្នុងបណ្តឹងឧទ្ធរណ៍នេះ។

ឃ្លាថា 'ឲ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន' <u>ត្រូវតែ</u>វាយតម្លៃលើភាពស្មុគស្មាញនៃបញ្ហាដែលកំពុងកើតឡើង ហើយបញ្ហាផ្សេងទៀតដែលគូភាគីបានប្រឈមមុខ។ គួរកត់សំគាល់ឃើញថា ខុសពីតុលាការអន្តរជាតិមួយចំនួន ត្រង់ថារយៈពេលកំណត់ជាក់លាក់សម្រាប់ដាក់សារណាជំទាស់នឹងបញ្ហាយុត្តាធិការ ត្រូវបានបង្កើតឡើងដោយនីតិវិធីដោយឡែកៗរបស់គេ ពុំមែនដូចរយៈពេលកំណត់ធ្វើឡើងនៅ អ.វ.ត.ក បែបនេះនោះទេ។

[...] សហមេធាវីការពារក្តីគ្មានបំណងចង់ដាក់សារណាអំពីបញ្ហាទាំងនេះឲ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាននោះទេ។ សហមេធាវីការពារក្តីលើកឡើងដោយគោរពថា "វាមិនចាត់ទុកជាផលប្រយោជន៍របស់លោក **អៀង សារី** ក្នុងការប្រញាប់ប្រញាល់ដាក់សារណាដែលមិនអាចទទួលយកបាន និងគ្មានរៀបចំត្រឹមត្រូវ ដែលអាចឲ្យគេបដិសេធដោយប្រសិទ្ធិភាពនូវសិទ្ធិជាមូលដ្ឋានរបស់លោក **អៀង សារី** ក្នុងការទទួលបានជំនួយពីមេធាវីដោយប្រសិទ្ធិភាព"[27]។

## ២) ការគ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ

សហមេធាវីការពារក្តីលើកឡើងនៅក្នុងសារណាររបស់ខ្លួនស្តីពីបញ្ហាយុត្តាធិការថា "អង្គជំនុំជម្រះវិសាមញ្ញ ពុំមានយុត្តាធិការជំនុំជម្រះលោក **អៀង សារី** ចំពោះបទឧក្រិដ្ឋដែលមានបញ្ជាក់ក្នុងសេចក្តីសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរឡើយ"[28]។

ទាក់ទងនឹងគោលការណ៍ *គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* សហមេធាវីការពារក្តីលើកឡើងថា "សហចៅក្រមស៊ើបអង្កេតមានកំហុសក្នុងការសម្រេចថា គោលការណ៍ [...] នេះ មិនអាចអនុវត្តបាន"[29]។ "*ការគ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* គឺជាគោលការណ៍មូលដ្ឋាននៃច្បាប់សិទ្ធិមនុស្ស ហើយត្រូវបានទទួលស្គាល់ដោយលិខិតតុបករណ៍អន្តរជាតិជាច្រើន រួមទាំងនីតិវិធីព្រហ្មទណ្ឌកម្ពុជាផងដែរ។ កិច្ចព្រមព្រៀងបង្កើត អ.វ.ត.ក ក៏បានចែងយ៉ាងច្បាស់ផងដែរថា 'គ្មានជនណាម្នាក់ត្រូវយកមកចោទប្រកាន់ ឬ យក

---

[27] កថាខណ្ឌទី១៥ ដល់១៧ នៃសំណើសុំជាបន្ទាន់នូវពេលវេលាសមស្របក្នុងការដាក់សារណាជំទាស់នឹងបញ្ហាយុត្តាធិការនិងឆ្លើយតបតាមការអញ្ជើញរបស់អង្គបុរេជំនុំជម្រះ ទៅនឹងសេចក្តីសន្និដ្ឋានរបស់ការិយាល័យសហដែលឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហមេធាវីការពារក្តីចំពោះការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ ២00៨។

[28] កថាខណ្ឌទី ៣ នៃសារណារបស់ **អៀង សារី** អនុលោមតាមសេចក្តីសម្រេចអំពីសំណើជាបន្ទាន់របស់សហមេធាវី ដែលស្នើសុំពន្យារពេលសមស្រប ក្នុងការដាក់សារណាជំទាស់នឹងបញ្ហាយុត្តាធិការ ចុះថ្ងៃទី 0៧ ខែមេសា ឆ្នាំ ២00៨។

[29] កថាខណ្ឌទី ៩ នៃសារណារបស់ **អៀង សារី** អនុលោមតាមសេចក្តីសម្រេចអំពីសំណើជាបន្ទាន់របស់សហមេធាវី ដែលស្នើសុំពន្យារពេលសមស្រប ក្នុងការដាក់សារណាជំទាស់នឹងបញ្ហាយុត្តាធិការ ចុះថ្ងៃទី 0៧ ខែមេសា ឆ្នាំ ២00៨។

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. * C.E.T.C.

00197695

C22/I/42



មកផ្តន្ទាទោសសារជាថ្មីឡើយចំពោះបទល្មើសដែលបានផ្តន្ទាទោសជាស្ថាពរ ឬបានលើកលែងទោសស្របតាមច្បាប់ និងនីតិវិធីព្រហ្មទណ្ឌរបស់រដ្ឋនីមួយៗរួចហើយ'។ [...] សហមេធាវីការពារក្តីលើកឡើងថា សិទ្ធិមិនត្រូវបានជំនុំជម្រះសារជាថ្មីចំពោះបទល្មើសតែមួយ ទទួលបានការការពារពីច្បាប់កម្ពុជា ដោយពុំមានអញ្ញត្រកម្មឡើយ។ ចំពោះកម្រិតដែលថាអញ្ញត្រកម្មដែលការិយាល័យសហចៅក្រមស៊ើបអង្កេតបានកំណត់ពិតជាមាន និងអនុវត្តបាននៅអ.វ.ត.កនោះ សហមេធាវីការពារក្តីលើកឡើងថា អញ្ញត្រកម្មទាំងនេះមិនអាចយកមកអនុវត្តបាននៅក្នុងរឿងក្តីនេះឡើយ។ [...] អញ្ញត្រកម្មទីមួយ [...] អនុញ្ញាតឱ្យមានការចោទប្រកាន់សារជាថ្មីបាន តែនៅពេលដែលដំណើរការរឿងក្តីពីមុនត្រូវបានធ្វើឡើង 'ក្នុងគោលបំណងការពារជនដែលពាក់ព័ន្ធឱ្យរួចផុតពីការទទួលខុសត្រូវប៉ុណ្ណោះ'។ ដោយសារតែការកាត់ទោសនៅឆ្នាំ១៩៧៩ បណ្តាលឱ្យមានការផ្តន្ទាទោសប្រហារជីវិតចំពោះលោក **អៀង សារី** និងរឹបអូសទ្រព្យសម្បត្តិទាំងអស់របស់គាត់ សហមេធាវីការពារក្តីលើកឡើងថាជាក់ស្តែងណាស់ ការកាត់ទោសនៅឆ្នាំ១៩៧៩ ពុំមានគោលបំណងការពារលោក **អៀង សារី** ឱ្យរួចផុតពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌឡើយ។ ដោយសារតែហេតុផលបែបនេះ អញ្ញត្រកម្មទីមួយនេះមិនអាចយកមកអនុវត្តបានឡើយ។ អញ្ញត្រកម្មទីពីរ [...]អាចយកមកអនុវត្តបាន ក្នុងករណីដែលដំណើរការរឿងក្តីពីមុន 'ពុំបានធ្វើឡើងដោយឯករាជ្យ ឬ ដោយអនាគតិ ស្របតាមបទដ្ឋាននៃនីតិវិធីត្រឹមត្រូវ ដែលច្បាប់អន្តរជាតិទទួលស្គាល់ ហើយធ្វើឡើងតាមរបៀប ដែលក្នុងកាលៈទេសៈខ្លះ វាមិនស្របនឹងគោលបំណងក្នុងការនាំជនដែលពាក់ព័ន្ធមកកាត់ទោស'។ ជាក់ស្តែងណាស់ ការកាត់ទោសនៅឆ្នាំ១៩៧៩ ពុំមានគោលបំណងជួយលោក **អៀង សារី** ឱ្យរួចផុតពីពិរុទ្ធភាពឡើយ ដោយសារតែគាត់ត្រូវបានផ្តន្ទាទោសប្រហារជីវិត និងរឹបអូសទ្រព្យសម្បត្តិទាំងអស់របស់គាត់។ ដោយសារតែហេតុផលបែបនេះ អញ្ញត្រកម្មទីពីរនេះមិនអាចយកមកអនុវត្តបានឡើយ"[30]។

លើសពីនេះ សហមេធាវីការពារក្តីលើកឡើងថា គោលការណ៍ ***គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ*** "មិនអាចយកមកអនុវត្តបាន តែនៅពេលដែលជនជាប់ចោទត្រូវបានចោទប្រកាន់ចំពោះ***បទល្មើស***ដដែល ដែលខ្លួនទទួលបានការជំនុំជម្រះពីមុនរួចហើយប៉ុណ្ណោះ។ ជាងនេះទៅទៀត គោលការណ៍នេះត្រូវបានយកមកអនុវត្តដើម្បីធ្វើជាឧបសគ្គរាំងកុំឱ្យមានការចោទប្រកាន់ ក្នុងករណីដែលជននោះទទួលបានការជំនុំជម្រះពីមុនរួចហើយនូវ***អំពើដដែល*** ។ គេអាចមើលឃើញគោលការណ៍នេះយ៉ាងច្បាស់នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលចែងថា 'ដោយអនុវត្តតាមគោលការណ៍អាជ្ញាអស់ជំនុំ ជនណាដែលត្រូវបានតុលាការសម្រេចឱ្យរួចខ្លួនជាស្ថាពរហើយ ជននោះមិនអាចត្រូវបានចោទប្រកាន់ទៀតចំពោះ***អំពើដដែល*** ទោះបីជាក្រោម***ការកំណត់ឈ្មោះបទល្មើសថ្មីផ្សេងក៏ដោយ*** ។ គោលការណ៍នេះមានបង្ហាញច្បាស់ដោយស្មើភាពគ្នានៅក្នុងលក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) លក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី

---

[30] កថាខណ្ឌទី១១, ១៣, ១៤ និង១៥ នៃសារណារបស់ **អៀង សារី** អនុលោមតាមសេចក្តីសម្រេចអំពីសំណើជាបន្ទាន់របស់សហមេធាវី ដែលស្នើសុំពន្យារពេលសមស្រប ក្នុងការដាក់សារណាជំទាស់នឹងបញ្ជាឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ០៧ ខែមេសា ឆ្នាំ ២០០៨។

(ICTY) និងលក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា (ICTR)"[31]។ ក្រៅពីនេះ សហមេធាវីការពារក្តីលើកឡើងថា "ទស្សនាទាននៃការផ្តន្ទាទោសត្រួតគ្នាមិនអាចយកមកអនុវត្តនៅទីនេះបានឡើយ ដោយសារមានតែសាលាក្តីអន្តរជាតិប៉ុណ្ណោះដែលបានប្រើការផ្តន្ទាទោសត្រួតគ្នា ក្នុងករណីដែលជនជាប់ចោទត្រូវបានចោទប្រកាន់ត្រួតគ្នាក្នុង*សវនាការជំនុំជម្រះដដែល*។ នៅក្នុងរឿងក្តីនេះ សវនាការជំនុំជម្រះទាំងពីរនេះត្រូវបានធ្វើឡើងដាច់ដោយឡែកពីគ្នាអស់ជិត៣០ឆ្នាំទៅហើយ។ ទោះបីជា ទស្សនាទាននៃការផ្តន្ទាទោសត្រួតគ្នាអាចយកមកអនុវត្តនៅទីនេះបានក៏ដោយ ការិយាល័យសហចៅក្រមស៊ើបអង្កេតគួរតែបានពិចារណាពីលក្ខណៈវិនិច្ឆ័យដែលអនុញ្ញាតឱ្យមានការផ្តន្ទាទោសត្រួតគ្នា ឱ្យបានលម្អិតជាងនេះ [...]"[32]។ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋសង្គ្រាម *ពុំ* តម្រូវឱ្យមានបង្ហាញពីធាតុផ្សំណាមួយដែលពុំចាំបាច់សម្រាប់បទល្មើសប្រល័យពូជសាសន៍ទេ។ ផ្ទុយទៅវិញ បទល្មើសប្រល័យពូជសាសន៍ *ពិតជា* តម្រូវឱ្យមានបង្ហាញពីចេតនាជាក់លាក់ដែលបទល្មើសផ្សេងមិនមាន។ ហេតុដូច្នេះ មានតែការផ្តន្ទាទោសក្រោមបទប្បញ្ញត្តិជាក់លាក់ជាងនេះ គឺ បទល្មើសប្រល័យពូជសាសន៍ប៉ុណ្ណោះ ទើបអាចយកមកគិតគូរនៅពេលធ្វើការពិចារណាពីគោលការណ៍នៃការផ្តន្ទាទោសត្រួតគ្នាបាន។ [...] ហេតុដូច្នេះ ជាលទ្ធផល វាបង្ហាញច្បាស់ថា ការផ្តន្ទាទោសលើកដំបូងរបស់លោក **អៀង សារី** ពីបទប្រល័យពូជសាសន៍នៅឆ្នាំ១៩៧៩ ការពារមិនឱ្យមានការចោទប្រកាន់លើគាត់ពេលក្រោយៗទៀត ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋសង្គ្រាម ដែលឈរលើមូលដ្ឋាននៃអង្គហេតុដូចគ្នា"[33]។

ជាទីបញ្ចប់ សហមេធាវីការពារក្តីលើកឡើងក្នុងចំណុចនេះថា "នៅក្នុងការពិភាក្សារបស់ខ្លួនអំពី *ការគ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* ចុងក្រោយ ការិយាល័យសហចៅក្រមស៊ើបអង្កេតអះអាងថា 'វាហាក់ដូចជាបង្ហាញរួចហើយថា សាលក្រមសម្រេចឆ្នាំ១៩៧៩ ពុំបានគ្របគ្រប់អំពើទាំងអស់ដែលបច្ចុប្បន្ន **អៀង សារី** កំពុងទទួលបានការចោទប្រកាន់នោះឡើយ'។ ប៉ុន្តែ តាមការទទួលស្គាល់របស់ការិយាល័យសហចៅក្រមស៊ើបអង្កេតខ្លួនឯង *ពុំមានការវិភាគស៊ីជម្រៅណាមួយធ្វើឡើង* អំពីការកាត់ទោសនៅឆ្នាំ១៩៧៩ឡើយ នៅពេលដែលចេញដីកាបង្គាប់ឱ្យឃុំខ្លួននោះ [...]។ មូលដ្ឋានអង្គហេតុនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះឆ្នាំ១៩៧៩ គ្របទៅលើបទល្មើសដែលបានចោទប្រកាន់ទាំងអស់ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ"[34]។

---

[31] កថាខណ្ឌទី១៦ នៃសារណារបស់ **អៀង សារី** អនុលោមតាមសេចក្តីសម្រេចអំពីសំណើជាបន្ទាន់របស់សហមេធាវី ដែលស្នើសុំពន្យារពេលសមស្រប ក្នុងការដាក់សារណាជំទាស់នឹងបញ្ហាយុត្តាធិការ ចុះថ្ងៃទី ០៧ ខែមេសា ឆ្នាំ ២០០៨។

[32] កថាខណ្ឌទី១៧ និង១៨ នៃសារណារបស់ **អៀង សារី** អនុលោមតាមសេចក្តីសម្រេចអំពីសំណើជាបន្ទាន់របស់សហមេធាវី ដែលស្នើសុំពន្យារពេលសមស្រប ក្នុងការដាក់សារណាជំទាស់នឹងបញ្ហាយុត្តាធិការ ចុះថ្ងៃទី ០៧ ខែមេសា ឆ្នាំ ២០០៨។

[33] កថាខណ្ឌទី២០ និង២១ នៃសារណារបស់ **អៀង សារី** អនុលោមតាមសេចក្តីសម្រេចអំពីសំណើជាបន្ទាន់របស់សហមេធាវី ដែលស្នើសុំពន្យារពេលសមស្រប ក្នុងការដាក់សារណាជំទាស់នឹងបញ្ហាយុត្តាធិការ ចុះថ្ងៃទី ០៧ ខែមេសា ឆ្នាំ ២០០៨។

[34] កថាខណ្ឌទី២៤ និង២៥ នៃសារណារបស់ **អៀង សារី** អនុលោមតាមសេចក្តីសម្រេចអំពីសំណើជាបន្ទាន់របស់សហមេធាវី ដែលស្នើសុំពន្យារពេលសមស្រប ក្នុងការដាក់សារណាជំទាស់នឹងបញ្ហាយុត្តាធិការ ចុះថ្ងៃទី ០៧ ខែមេសា ឆ្នាំ ២០០៨។

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE ECCC CETC

សហព្រះរាជអាជ្ញាលើកឡើងថា “មាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) ដែលយកមកអនុវត្តនៅតុលាការនេះ ហាមឃាត់ *ការគ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* ។ [...] ប៉ុន្តែ គោលការណ៍នេះមានករណីអញ្ញត្រកម្ម។ [...] ដោយឆ្លុះបញ្ចាំងពីភាពច្បាស់លាស់នៃនីតិអន្តរជាតិ លក្ខន្តិកៈនៃសាលាក្តីអន្តរជាតិចែងថា *ការគ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* មិនអាចយកមកអនុវត្តបានទេនៅពេលសាលាក្តីអន្តរជាតិធ្វើការចោទប្រកាន់លើកទីពីរ បន្ទាប់ពីមានការចោទប្រកាន់លើកទីមួយនៅយុត្តាធិការជាតិមិនបានធ្វើឡើងដោយឯករាជ្យ ឬអនាគតិ ស្របតាមបទដ្ឋាននៃនីតិវិធីច្បាប់ដែលមានការទទួលស្គាល់ជាអន្តរជាតិ ឬធ្វើឡើងតាមលក្ខណៈមិនស្របនឹងគោលបំណងក្នុងការនាំជនជាប់ចោទមកកាត់ទោស”[35]។

សហព្រះរាជអាជ្ញាលើកឡើងថា “តុលាការប្រជាជនបដិវត្តមិនបានឆ្លើយតបនឹងការការពារអន្តរជាតិនៃការជំនុំជម្រះត្រឹមត្រូវនោះទេ។ ទីមួយ ក្រឹត្យច្បាប់ដែលបង្កើតតុលាការប្រជាជនបដិវត្ត ពុំបានប្រកាសឲ្យប្រើប្រាស់ដោយស្ថាប័ននីតិបញ្ញត្តិឡើយ។ [...] ទីពីរ តុលាការប្រជាជនបដិវត្តត្រូវបានបង្កើតឡើងដោយប្រញាប់ប្រញាល់ និងទំនងជាមានគោលបំណងតែមួយគត់គឺ ‘បិរហារបនប៉ុលពត-អៀង សារី’ បន្ទាប់ពីបណ្តេញពួកខ្មែរក្រហមចេញពីអំណាចភ្លាម។ ទីបី តុលាការប្រជាជនបដិវត្តបានសន្មតជាមុនថាជនជាប់ចោទមានពិរុទ្ធភាព (មានទោស) មុននឹងចេញសាលក្រមសម្រេច។ [...] ទីបួន តុលាការប្រជាជនបដិវត្តពុំបានកាត់ទោសជនជាប់ចោទនៅចំពោះមុខទេ។ [...] ទីប្រាំ សាលក្រមសម្រេចផ្តន្ទាទោសរបស់តុលាការប្រជាជនបដិវត្តពុំទាន់បានចូលស្ថាពរឡើយ ដោយសារតែក្រឹត្យច្បាប់មិនបានផ្តល់សិទ្ធិប្តឹងឧទ្ធរណ៍ដល់ជនជាប់ចោទ”[36]។

សហព្រះរាជអាជ្ញាលើកឡើងបន្ថែមថា “ការចោទប្រកាន់ចុងចោទជាលើកទីពីរចំពោះបទល្មើសខុសគ្នាដែលផ្អែកលើអំពើព្រហ្មទណ្ឌដដែល មិនបានរំលោភលើគោលការណ៍ *គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* នោះទេ ដរាបណាភាពមិនត្រឹមត្រូវណាមួយកើតចេញពីការផ្តន្ទាទោសទ្វេរដង ត្រូវបានយកមកជាប្រយោជន៍សម្រាប់ការដាក់ទោស។ សាលាក្តីអន្តរជាតិអនុញ្ញាតឲ្យមានការផ្តន្ទាទោសច្រើនដង ចំពោះអំពើតែមួយដដែល (ឬ អំពីអកម្ម) ក្នុងករណីដែលបង្ហាញច្បាស់ថា មានការរំលោភលើបទប្បញ្ញត្តិខុសៗគ្នាជាច្រើននៃលក្ខន្តិកៈសម្រាប់ធ្វើការចោទប្រកាន់ មានន័យថា ក្នុងករណីដែលបទប្បញ្ញត្តិនីមួយៗមានធាតុផ្សំខុសៗគ្នាដែលតម្រូវឲ្យមានការបង្ហាញអង្គហេតុខុសគ្នាជាសត្យានុម័ត។[...] គោលការណ៍នេះបំរើឲ្យគោលបំណងពីរ គឺវាធានា

---

[35] កថាខណ្ឌទី ៧ និង៨ នៃសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ១៦ ខែឧសភា ឆ្នាំ ២០០៨ ដែលឆ្លើយតបទៅនឹងសារណា របស់ **អៀង សារី** ស្តីពីយុត្តាធិការ។

[36] កថាខណ្ឌទី១៣ ដល់ ១៦ នៃសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ១៦ ខែឧសភា ឆ្នាំ២០០៨ ដែលឆ្លើយតបទៅនឹងសារណា របស់ **អៀង សារី** ស្តីពីយុត្តាធិការ។

ថា ចុងចោទទទួលបានការផ្តន្ទាទោសតែចំពោះបទល្មើសខុសៗគ្នាប៉ុណ្ណោះ ហើយធានាថា ការផ្តន្ទាទោសនោះឆ្លុះបញ្ចាំងយ៉ាងពេញលេញអំពីឧក្រិដ្ឋភាពរបស់ចុងចោទ”[37]។

សហព្រះរាជអាជ្ញាលើកឡើងបន្ថែមថា “ធាតុផ្សំអត្តនោម័ត និងសត្យានុម័តនៃអំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមានលក្ខណៈខុសគ្នាលើទិដ្ឋភាពសំខាន់ៗជាច្រើន។ ចំពោះធាតុសត្យានុម័ត ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមានវិសាលភាពទូលំទូលាយជាង ដោយសារវាអាចគ្របលើអំពើទាំងឡាយណាដែលមិនស្ថិតនៅក្នុងរង្វង់នៃអំពើប្រល័យពូជសាសន៍[...]។ ចំណែកធាតុអត្តនោម័ត ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតម្រូវឱ្យមានចេតនាប្រព្រឹត្តបទល្មើសដែលជាដើមហេតុ បន្ថែមទៅលើការយល់ដឹងពីការអនុវត្តជាទូទៅ ឬជាប្រព័ន្ធដែលបង្កើតបានជាបរិបទទូទៅនៃបទល្មើស។ ចំពោះអំពើប្រល័យពូជសាសន៍ អ្វីដែលចាំបាច់នោះ គឺជាចេតនាជាពិសេសក្នុងការបំផ្លិចបំផ្លាញទាំងស្រុង ឬ មួយផ្នែកនៃក្រុមពិសេសជាក់លាក់ណាមួយ ក្រៅពីចេតនាប្រព្រឹត្តបទល្មើសដែលជាដើមហេតុ”[38]។

មេធាវីដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងថា “ដើម្បីបកស្រាយគោលការណ៍ *ការគ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* និងអញ្ញត្រកម្មរបស់គោលការណ៍នេះដែលទទួលស្គាល់ជាអន្តរជាតិនោះ គួរតែយកលក្ខន្តិកៈនៃសាលាក្តីអន្តរជាតិមកធ្វើការពិចារណា”[39]។

“ទាក់ទងនឹងមាត្រា ២០(៣) ចំណុច (ក) និង (ខ) នៃលក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ បទប្បញ្ញត្តិនានាចំពោះអញ្ញត្រកម្មមានដូចតទៅ: ប្រសិនបើតុលាការផ្សេងមួយទៀតលាក់បំបាំងជនដែលពាក់ព័ន្ធ ឬប្រសិនបើការជំនុំជម្រះក្តីមិនបានប្រព្រឹត្តទៅដោយមិនឯករាជ្យ ***ឬ*** ដោយលំអៀង ផ្ទុយទៅនឹងបទដ្ឋាននីតិវិធីដែលទទួលស្គាល់ដោយច្បាប់អន្តរជាតិ ***ហើយ*** ត្រូវបានធ្វើឡើងតាមរបៀបមួយដែលមិនស្របនឹង [គោលបំណង] នាំខ្លួនជនដែលពាក់ព័ន្ធនោះមកកាត់ទោស។ [...] អាស្រ័យហេតុនេះ ការជំនុំជម្រះឆ្នាំ ១៩៧៩ ត្រូវតែពិនិត្យឱ្យបានស៊ីជម្រៅ ដើម្បីកំណត់ថាតើការផ្តន្ទាទោសលើកមុនរបស់ជនត្រូវចោទ គឺជាការរារាំងដល់ការចោទប្រកាន់នាពេលបច្ចុប្បន្នដែរ ឬទេ”[40]។

---

[37] កថាខណ្ឌទី១០ និង១២ នៃសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ១៦ ខែឧសភា ឆ្នាំ ២០០៨ ដែលឆ្លើយតបទៅនឹងសារណារបស់ **អៀង សារី** ស្តីពីយុត្តាធិការ។

[38] កថាខណ្ឌទី១៩ និង២០ នៃសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ១៦ ខែឧសភា ឆ្នាំ ២០០៨ ដែលឆ្លើយតបទៅនឹងសារណារបស់ **អៀង សារី** ស្តីពីយុត្តាធិការ។

[39] កថាខណ្ឌទី១៧ នៃសារណាតបរួមរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ ២០០៨ ដែលឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់ **អៀង សារី** ជំទាស់នឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន។

[40] កថាខណ្ឌទី២២ និង២៣ នៃសារណាតបរួមរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ ២០០៨ ដែលឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់ **អៀង សារី** ជំទាស់នឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន។

មេធាវីដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងបន្ថែមទៀតថា "ការរំលោភបំពានធ្ងន់ធ្ងរជាច្រើនលើសិទ្ធិជនជាប់ចោទ នាំឱ្យយើងឈានដល់ការសន្និដ្ឋានបានថា ការជំនុំជម្រះកាលពីមុនមិនអាចមានអានុភាពមកដល់ពេលបច្ចុប្បន្នបានទេ។ គោលការណ៍ជាមូលដ្ឋាននៃការទទួលបានការជំនុំជម្រះដោយតុលាការឯករាជ្យ និងឥតលំអៀង ត្រូវបានគេរំលោភ។ [...] ជនត្រូវចោទមិនអាចយោងដោយមានប្រសិទ្ធភាពទៅរកការកាត់ទោសឆ្នាំ ១៩៧៩ ពីមុនបានទេ ហើយក៏មិនអាចពឹងផ្អែកលើគោលការណ៍ *ការគ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* បានដែរ"[41]។

### ៣) ព្រះរាជានការអនុគ្រោះទោស និងការលើកលែងទោស

សហមេធាវីការពារក្តីលើកឡើងថា ដោយផ្ទុយនឹងសំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេត "ច្បាប់ឆ្នាំ១៩៩៤ [...] *ប្រាកដជា* គ្របដណ្តប់ទៅលើបទឧក្រិដ្ឋទាំងឡាយដែល 'ស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក'។ អ.វ.ត.ក មានយុត្តាធិការទៅលើបទឧក្រិដ្ឋមនុស្សឃាត ការធ្វើទារុណកម្ម ការធ្វើទុកខបុកម្នេញលើសាសនា អំពីប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការរំលោភយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិវប្បធម៌ និងឧក្រិដ្ឋកម្មប្រឆាំងអ្នកដែលទទួលបានការការពារជាអន្តរជាតិ ។ បុព្វកថានៃច្បាប់ឆ្នាំ ១៩៩៤ មិនមែនគ្រាន់តែ 'និយាយសំដៅទៅលើអំពើប្រល័យពូជសាសន៍' ប៉ុណ្ណោះទេ ប៉ុន្តែវាចែងយ៉ាងច្បាស់ថា ច្បាប់នេះត្រូវបានអនុម័តឡើង 'ដោយយល់ថា មេដឹកនាំនៃក្រុមកម្ពុជាប្រជាធិបតេយ្យ' មិនអាច...*លាក់បំបាំងយករួចខ្លួនពីការទទួលខុសត្រូវរបស់ពួកខ្លួនដែលបានប្រព្រឹត្តឧក្រិដ្ឋកម្ម ភេរវកម្ម និងអំពើប្រល័យពូជសាសន៍* ចាប់តាំងពីពេលរបបប៉ុលពត ដណ្តើមអំណាចនៅឆ្នាំ១៩៧៥-១៩៧៨។ *បទឧក្រិដ្ឋប្រល័យពូជសាសន៍គ្មានអាជ្ញាយុកាលឡើយ* ។ បុព្វកថានេះក៏ពន្យល់ប្រាប់ផងដែរថា ពួកខ្មែរក្រហមបានប្រព្រឹត្តជាបន្តបន្ទាប់នូវ 'ឧក្រិដ្ឋកម្ម ភេរវកម្ម និងអំពើប្រល័យពូជសាសន៍ ដែលជាចរិកពិតរបស់ក្រុមខ្លួន តាំងពីក្រុមខ្លួនដណ្តើមយកអំណាចកាន់កាប់នីឆ្នាំ ១៩៧៥ [...]' ។ ហេតុដូច្នេះ ឧក្រិដ្ឋកម្មដែលបានសំដៅនៅក្នុងច្បាប់នេះមានលក្ខណៈទូលំទូលាយជាងការលើកឡើងរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត។ មាត្រា ៣ និង៤ នៃច្បាប់ឆ្នាំ ១៩៩៤ រៀបរាប់ពីឧក្រិដ្ឋកម្មថែមទៀតថា ច្បាប់នេះមានគោលបំណងក្តោបទៅលើអំពើរួមមាន អំពីមនុស្សឃាតដោយចេតនា អំពីរំលោភសេពសន្ថវៈ អំពីប្លន់ ការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ និងការកាន់អាវុធប្រឆាំងនឹងអាជ្ញាធរសាធារណៈ។ ច្បាស់ណាស់ថា ការរៀបរាប់បទល្មើសខាងលើនេះមិនទាន់អស់នៅឡើយទេ ព្រោះថា មាត្រា ៣ បញ្ចប់ការរៀបរាប់បទល្មើសក្នុងមាត្រានេះ ដោយពាក្យថា '។ល។' ដោយសារតែការរៀបរាប់បទល្មើសមិនទាន់អស់នេះហើយ

---

[41] កថាខណ្ឌទី២៨ នៃសារណាតបរួមរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ ២០០៨ ដែលឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់ **អៀង សារី** ជំទាស់នឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន។

PRE-TRIAL CHAMBER * CHAMBRE PRELIMINAIRE E.C.C.C * C.E.T.C

ទើបគោលបំណង និងវិសាលភាពរបស់ច្បាប់នេះ ដូចដែលបានពិភាក្សាក្នុងបុព្វកថា គួរត្រូវបានយកមកធ្វើការពិចារណា។មានការគាំទ្រយ៉ាងច្បាស់លាស់ផងដែរពីការអនុវត្តច្បាប់ឆ្នាំ ១៩៩៤ ចំពោះការចោទប្រកាន់សមាជិកខ្មែរក្រហមដទៃទៀតពីបទឧក្រិដ្ឋមនុស្សឃាត ដែលវាមានគោលបំណងយ៉ាងពេញលេញក្នុងការគ្របដណ្តប់លើឧក្រិដ្ឋកម្មដូចគ្នា ដោយសារតែឧក្រិដ្ឋកម្មទាំងនោះស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ពោលគឺឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តក្នុងអំឡុងពេលពីថ្ងៃទី១៧ ខែមេសា ឆ្នាំ ១៩៧៥ រហូតដល់ ថ្ងៃទី៦ ខែមករា ឆ្នាំ ១៩៧៩។ [...] សហមេធាវីការពារក្តីលើកឡើងថា ច្បាប់ឆ្នាំ ១៩៩៤ មានគោលបំណងធ្វើជាច្បាប់ជាក់លាក់ដើម្បីកាត់សេចក្តីនូវបទល្មើសដែលបានប្រព្រឹត្តដោយខ្មែរក្រហម ដែលជាមូលដ្ឋានតែមួយគាត់សម្រាប់ធ្វើការកាត់សេចក្តីដល់សមាជិកខ្មែរក្រហម។ [...] ការលើកលែងទោសរបស់លោក **អៀង សារី** ផ្តល់អភ័យឯកសិទ្ធិពិសេសដល់លោក **អៀង សារី** ឱ្យរួចផុតពីការចោទប្រកាន់ចំពោះឧក្រិដ្ឋកម្មដែលបានកំណត់ដោយច្បាប់ឆ្នាំ ១៩៩៤ ហើយជាការជាក់ច្បាស់ណាស់ដែលថាឧក្រិដ្ឋកម្មទាំងនេះមានលក្ខណៈដូចគ្នានឹងឧក្រិដ្ឋកម្មដែលឥឡូវនេះកំពុងតែស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក។ ហេតុដូច្នេះ ទាក់ទងនឹងឧក្រិដ្ឋកម្មទាំងនេះ ច្បាប់ឆ្នាំ១៩៩៤ រារាំងមិនឱ្យ អ.វ.ត.ក មានយុត្តាធិការលើលោក **អៀង សារី** បានឡើយ"[42]។

សហព្រះរាជអាជ្ញាលើកឡើងថា "ការលើកលែងទោសដែលផ្តល់ទៅឱ្យជនត្រូវចោទរូបនេះឱ្យរួចផុតពីការចោទប្រកាន់ក្នុងពេលអនាគត ដែលស្ថិតនៅក្រោមច្បាប់ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឱ្យនៅក្រៅច្បាប់ មិនអាចយកមកអនុវត្តនៅតុលាការនេះបានឡើយ។ ច្បាប់ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឱ្យនៅក្រៅច្បាប់មានទស្សនៈវិស័យផ្តន្ទាទោសជាបទល្មើសព្រហ្មទណ្ឌចំពោះសមាជិកខ្មែរក្រហមចាប់ពីរយៈពេល៦ខែបន្ទាប់ពីអនុម័តច្បាប់នេះ។ ច្បាប់នេះចែងសំដៅទៅរកជនណា 'ដែលប្រព្រឹត្ត' នូវសកម្មតស៊ូប្រឆាំងនឹងរដ្ឋ (មិនបានចែងថា *ជនណាដែលបានប្រព្រឹត្ត* នោះទេ)។ ម្យ៉ាងវិញទៀត ច្បាប់បង្កើត អ.វ.ត.ក ចែងផ្តល់យុត្តាធិការពេលវេលាដល់តុលាការនេះយ៉ាងតឹងរ៉ឹងចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅចន្លោះថ្ងៃទី១៧ ខែមេសា ឆ្នាំ ១៩៧៥ និងថ្ងៃទី៦ ខែមករា ឆ្នាំ ១៩៧៩។ ហេតុដូច្នេះ ឧក្រិដ្ឋកម្មដែលអាចចោទប្រកាន់បានតាមច្បាប់ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឱ្យនៅក្រៅច្បាប់ គឺវាស្ថិតនៅហួសពីយុត្តាធិការពេលវេលារបស់តុលាការនេះទៅទៀត"[43]។

សហព្រះរាជអាជ្ញាលើកឡើងបន្ថែមទៀតថា "ដោយផ្ទុយពីការអះអាងរបស់ខ្លួន ជនត្រូវចោទរូបនេះពុំបាន

---

[42] កថាខណ្ឌទី២៦ ដល់ ៣៥ នៃសារណារបស់ **អៀង សារី** អនុលោមតាមសេចក្តីសម្រេចអំពីសំណើជាបន្ទាន់របស់សហមេធាវី ដែលស្នើសុំពន្យារពេលសមស្រប ក្នុងការដាក់សារណាជំទាស់នឹងបញ្ហាយុត្តាធិការ ចុះថ្ងៃទី ០៧ ខែមេសា ឆ្នាំ ២០០៨។

[43] កថាខណ្ឌទី៣៣ នៃសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ដែលឆ្លើយតបទៅនឹងសារណារបស់ **អៀង សារី** ស្តីពីយុត្តាធិការ ចុះថ្ងៃទី ១៦ ខែឧសភា ឆ្នាំ ២០០៨។

ទទួលការអនុគ្រោះទោសឱ្យរួចពីការផ្តន្ទាទោសណាមួយពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ឡើយ។ ភាសាដែលប្រើនៅក្នុងការអនុគ្រោះទោសមានលក្ខណៈចង្អៀត និងជាក់លាក់។ ការអនុគ្រោះទោសមានការកម្រិតទៅលើវិសាលភាពដែលអនុញ្ញាតឱ្យជនត្រូវចោទរូបនេះរួចផុតពីការ 'ផ្តន្ទាទោសប្រហារជីវិត និងរឹបអូសទ្រព្យសម្បត្តិទាំងអស់របស់ខ្លួន' តែប៉ុណ្ណោះ។ វាមិនបានសំដៅទៅរកការប្រព្រឹត្តិ ឬបទល្មើសណាមួយដែលជនត្រូវចោទទទួលបានការអនុគ្រោះនោះទេ ហេតុដូច្នេះ វាមិនបានអនុគ្រោះឱ្យជនត្រូវចោទរួចផុតពី 'ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ឡើយ'។ ហើយចំពោះបទល្មើសផ្សេងៗទៀតដែលជនត្រូវចោទអាចបានប្រព្រឹត្តក្នុងចន្លោះពេលពីឆ្នាំ ១៩៧៥ ដល់ ១៩៧៩ ក៏មិនបានទទួលការអនុគ្រោះនោះដែរ។ អាស្រ័យហេតុនេះ ការអនុគ្រោះនេះមិនមែនជាការរាំងដល់ការចោទប្រកាន់ជនត្រូវចោទចំពោះឧក្រិដ្ឋកម្មណាមួយដែលស្ថិតនៅក្នុងដែនយុត្តាធិការរបស់តុលាការនេះដែរ"[44]។

សហព្រះរាជអាជ្ញាលើកឡើងថា " [...] ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ គឺជាឧក្រិដ្ឋកម្មដែលមានកម្រិតជាបទដ្ឋានអាជ្ញាបញ្ញា (jus cogens crime) ។ មិនអនុញ្ញាតឱ្យមានការអនុគ្រោះទោសណាមួយចំពោះឧក្រិដ្ឋកម្មអន្តរជាតិធ្ងន់ធ្ងរបែបនេះឡើយ។ ហេតុដូច្នេះ ព្រះរាជទានអនុគ្រោះទោសចំពោះការផ្តន្ទាទោសជនត្រូវចោទរូបនេះនៅឆ្នាំ ១៩៧៩ ពុំមានសុពលភាពឡើយ"[45]។

ចុងបញ្ចប់ សហព្រះរាជអាជ្ញាលើកឡើងថា "ក្នុងនាមជាសាលាក្តីពិសេសដែលមានលក្ខណៈជាអន្តរជាតិដែលជាប់កាតព្វកិច្ចត្រូវអនុវត្តច្បាប់អន្តរជាតិ ការអនុគ្រោះទោសថ្នាក់ជាតិណាមួយ (ទោះបីជាទទួលបានដោយសុពលភាពក៏ដោយ) ក៏មិនអាចយកមកអនុវត្តក្នុងការកាត់សេចក្តីឧក្រិដ្ឋកម្មអន្តរជាតិដែលមានកម្រិតជាបទដ្ឋានអាជ្ញាបញ្ញានៅតុលាការនេះបានឡើយ។ [...] ហេតុដូច្នេះ ស្របតាមសេចក្តីសម្រេចរបស់តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន (SCSL) ក្នុងរឿងក្តី *Kallon* ដែលយល់ឃើញថា ការអនុគ្រោះទោសថ្នាក់ជាតិចំពោះឧក្រិដ្ឋកម្មអន្តរជាតិមិនអាចជាការរាំងដល់ការកាត់សេចក្តីនូវឧក្រិដ្ឋកម្មទាំងនោះនៅសាលាក្តីអន្តរជាតិបានឡើយ។ ការអនុគ្រោះទោសថ្នាក់ជាតិណាមួយ ចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដែលជាឧក្រិដ្ឋកម្មមានកម្រិតជាបទដ្ឋានអាជ្ញាបញ្ញាមិនអាចយកមកអនុវត្តនៅតុលាការនេះបានទេ"[46]។

មេធាវីដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងថា "អនុលោមតាមមាត្រា ២៧ នៃរដ្ឋធម្មនុញ្ញ ព្រះមហាក្សត្រពុំមានព្រះរាជសិទ្ធិប្រកាស 'ការលើកលែងទោស' ឱ្យរួចផុតពីការចោទប្រកាន់ជាពិសេសណាមួយក្នុងពេលអនាគត

[44] កថាខណ្ឌទី៣៥ នៃសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ដែលឆ្លើយតបទៅនឹងសារណារបស់ **អៀង សារី** ស្តីពីយុត្តាធិការ ចុះថ្ងៃទី ១៦ ខែឧសភា ឆ្នាំ ២០០៨។

[45] កថាខណ្ឌទី៣៨ នៃសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ដែលឆ្លើយតបទៅនឹងសារណារបស់ **អៀង សារី** ស្តីពីយុត្តាធិការ ចុះថ្ងៃទី ១៦ ខែឧសភា ឆ្នាំ ២០០៨។

[46] កថាខណ្ឌទី៣៩ និង៤០ នៃសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាដែលឆ្លើយតបទៅនឹងសារណារបស់ **អៀង សារី** ស្តីពីយុត្តាធិការ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ ២០០៨។

E.C.C.C * C.E.T.C PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE

ដោយគ្មានការផ្តន្ទាទោសជាមុនបានឡើយ។ [...] ហេតុដូច្នេះ ព្រះមហាក្សត្រទ្រង់បានអនុវត្តព្រះរាជសិទ្ធិរបស់ព្រះអង្គហួសពីព្រះរាជសិទ្ធិដែលបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ ដោយព្រះអង្គទ្រង់បានព្រះរាជទាន 'ការលើកលែងទោស' ដល់ជនត្រូវចោទឱ្យរួចផុតពីទោសដែលបានកំណត់ដោយច្បាប់ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឱ្យនៅក្រៅច្បាប់។ 'ការលើកលែងទោស' ដែលមិនមានលក្ខណៈស្របច្បាប់ មិនចងកាតព្វកិច្ចដល់ អ.វ.ត.ក ហើយក៏គ្មានការរារាំងដល់ការកាត់សេចក្តីដែរ"[47]។ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងបន្ថែមទៀតថា "នៅពេលសន្មតថា ព្រះរាជទានការលើកលែងទោសរបស់ព្រះមហាក្សត្របែបនេះស្ថិតនៅក្នុងព្រះរាជសិទ្ធិអំណាចរបស់ព្រះអង្គតាមរដ្ឋធម្មនុញ្ញ ការទទួលយកព្រះរាជទានការលើកលែងទោសនេះមានន័យថាជានិទណ្ឌភាព។ ចាប់តាំងពីមានការបង្កើតឱ្យមានសាលាក្តីពិសេសអន្តរជាតិ និងតុលាការព្រហ្មទណ្ឌអន្តរជាតិ ព្រមទាំងដំណើរការជោគជ័យដ៏ទូលំទូលាយ ជាពិសេសនៅក្នុងអាមេរិកឡាទីនប្រឆាំងនឹងនិទណ្ឌភាពរបស់ប្រមុខរដ្ឋ និងអ្នកទទួលខុសត្រូវខ្ពស់បំផុត ការរារាំងជាទូទៅដល់ការកាត់សេចក្តីចំពោះឧក្រិដ្ឋកម្មធ្ងន់ធ្ងរបំផុត សហគមន៍អន្តរជាតិលែងទទួលស្គាល់ទៀតហើយ"[48]។ "ឧទាហរណ៍ទាំងនេះបង្ហាញថា ទោះបីជាការលើកលែងទោសរបស់ព្រះមហាក្សត្រ គួរតែបកស្រាយថាស្ថិតនៅក្នុងដែនព្រះរាជសិទ្ធិអំណាចរបស់ព្រះអង្គតាមរដ្ឋធម្មនុញ្ញក៏ដោយ ក៏ការលើកលែងទោសនេះមិនស្របតាមបទដ្ឋានអន្តរជាតិ ដូច្នេះហើយវាមិនមែនជាលិខិតុបករណ៍ចងកាតព្វកិច្ចនៅ អ.វ.ត.ទេ"[49]។

ទាក់ទងនឹងការអនុគ្រោះទោស មេធាវីដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងថា "ព្រះរាជទានការអនុគ្រោះទោសរបស់ព្រះមហាក្សត្រគ្មានអត្ថន័យផ្សេងទៀតទេ ប្រសិនបើសេចក្តីសម្រេចឆ្នាំ ១៩៧៩ មិនបានអនុលោមតាមបទដ្ឋាននៃភាពមិនលំអៀង និងឯករាជ្យភាពរបស់តុលាការប្រជាជនបដិវត្ត ដូច្នេះវាមិនរារាំងដល់ការកាត់សេចក្តីត្រឹមត្រូវពិតប្រាកដបានទេ"[50]។

### ៤) ការយល់ឃើញថា ការឃុំខ្លួនបណ្តោះអាសន្នគឺជាវិធានការចាំបាច់

ការឃុំខ្លួនបណ្តោះអាសន្នក្នុងរឿងក្តីនេះ ត្រូវបានអនុវត្តតាមវិធាន ៦៣ នៃវិធានផ្ទៃក្នុង។ វិធាន ៦៣- ៣ ចែងអំពីមូលហេតុដែលសហចៅក្រមស៊ើបអង្កេតអាចចេញដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នបាន។

---

[47] កថាខណ្ឌទី៣២ និង៣៣ នៃសារណាតបរួមរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី ២០ ខែឧសភា ឆ្នាំ ២០០៨ ដែលឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់ **អៀង សារី** ជំទាស់នឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន។

[48] កថាខណ្ឌទី៣៥ នៃសារណាតបរួមរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី ២០ ខែឧសភា ឆ្នាំ ២០០៨ ដែលឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់ **អៀង សារី** ជំទាស់នឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន។

[49] កថាខណ្ឌទី៤១ នៃសារណាតបរួមរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី ២០ ខែឧសភា ឆ្នាំ ២០០៨ ដែលឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់ **អៀង សារី** ជំទាស់នឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន។

[50] កថាខណ្ឌទី៤២ នៃសារណាតបរួមរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី ២០ ខែឧសភា ឆ្នាំ ២០០៨ ដែលឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់ **អៀង សារី** ជំទាស់នឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន។

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

វិធាន ៦៣-៣ តម្រូវឲ្យមានអត្ថិភាពទាំងពីរ:

ក-មានមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់ច្បាស់ថា ជនត្រូវចោទធ្លាប់បានប្រព្រឹត្តបទល្មើស មួយ ឬ ច្រើន ដូចមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ

ខ-ការយល់ឃើញពីមូលហេតុដែលធ្វើឲ្យការឃុំខ្លួនបណ្តោះអាសន្នគឺជាវិធានការចាំបាច់

នៅក្នុងរឿងក្តីនេះ ភាគីមិនឯកភាពគ្នាលើមូលដ្ឋាននៃអង្គហេតុដែលមានលក្ខណៈចាំបាច់សម្រាប់ការយល់ឃើញពីវត្តមាននៃមូលហេតុដែលធ្វើឲ្យការឃុំខ្លួនបណ្តោះអាសន្នគឺជាវិធានការចាំបាច់។

សហមេធាវីការពារក្តីលើកឡើងថា "សហចៅក្រមស៊ើបអង្កេតបានរំលោភបំពានលើឆន្ទានុសិទ្ធិរបស់ខ្លួន ដោយការសំអាងសេចក្តីរបស់ខ្លួនទៅលើវិចារណញ្ញាណអរូបី និងលើទស្សនៈយល់ឃើញជាទូទៅ ដោយមិនពឹងផ្អែកលើអង្គហេតុឡើយ។ ការធ្វើបែបនេះ សហចៅក្រមស៊ើបអង្កេតបានធ្វើឲ្យមានកំហុសខាងអង្គហេតុ និងបានរំលោភបំពានបទដ្ឋានយុត្តិធម៌អន្តរជាតិ"[51]។

សហព្រះរាជអាជ្ញាលើកឡើងថា "ការសន្និដ្ឋានបែបនេះមិនបានឆ្លុះបញ្ចាំងពីការអនុវត្ត និងនីតិវិធីរបស់សាលាក្តីនេះបានត្រឹមត្រូវទេ ជាពិសេសការធ្វើសេចក្តីសម្រេចរបស់សាលាក្តីនេះ។ ពេលដែលសហចៅក្រមស៊ើបអង្កេតមានកាតព្វកិច្ចចេញដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នដោយមានសំអាងហេតុ បន្ទាប់ពីមានសវនាការតទល់គ្នា សហចៅក្រមស៊ើបអង្កេតមិនជាប់កាតព្វកិច្ចត្រូវចង្អុលបង្ហាញឲ្យបានគ្រប់ចំណុចទាំងអស់នៃភស្តុតាងដែលមាន ដើម្បីគាំទ្រសេចក្តីសន្និដ្ឋានរបស់ខ្លួនឡើយ។ ប្រាកដណាស់ ការពិសោធន៍សាកល្បងធ្វើឡើងគឺដើម្បីចង់ដឹងថាតើភស្តុតាងបែបនេះមាននៅក្នុងសំណុំរឿងដែរឬទេ។ នៅក្នុងរឿង **អៀង សារី** ជាការច្បាស់ណាស់ថា មានភស្តុតាងច្រើនសន្ធឹកសន្ធាប់ដើម្បីឆ្លើយតបការសាកល្បងនោះ"[52]។

មេធាវីដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងថា "អង្គបុរេជំនុំជម្រះអាចបដិសេធត្រឹមតែសេចក្តីសម្រេចរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតប៉ុណ្ណោះ ប្រសិនបើសហចៅក្រមស៊ើបអង្កេតមានការភ័ន្តច្រឡំ និងរំលោភបំពានឆន្ទានុសិទ្ធិរបស់ខ្លួន និយាយដោយសង្ខេបទៅ គឺប្រសិនបើសេចក្តីសម្រេចនោះ "ខុស មិនសមហេតុផល និង

[51] កថាខណ្ឌទី ២១ , ២៦, ៣១ និង៣៦ នៃសារណាបណ្តឹងឧទ្ធរណ៍ របស់ **អៀង សារី** ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៨ ចំពោះដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ។

[52] កថាខណ្ឌទី១២ នៃសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ដែលឆ្លើយតបទៅនឹងសារណារបស់ **អៀង សារី** ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៨ ចំពោះដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ។

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C.

គ្មានភស្តុតាងគាំទ្រគ្រប់គ្រាន់”[53]។

លើសពីនេះ ទាក់ទងនឹងមូលហេតុទាំងនេះ គូភាគីមិនមានការឯកភាពគ្នាទេ ជាពិសេសអំពីការសាកល្បងទាក់ទងនឹងវិធាន ៦៣ (ខ) (៥) ដែលចែងពីមូលដ្ឋាននៃ“ការរក្សាសណ្តាប់ធ្នាប់សាធារណៈ”។

សហមេធាវីការពារក្តីអះអាងថា “អនុលោមតាមនិយាមអន្តរជាតិ ហេតុផលផ្នែកសណ្តាប់ធ្នាប់សាធារណៈអាចត្រូវបានប្រើប្រាស់បានតែនៅពេលណាមានអង្គហេតុបង្ហាញថា ការដោះលែងជនសង្ស័យអាចប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈពិតប្រាកដ ហើយការឃុំខ្លួនជាគោលនយោបាយតែមួយគត់ ដើម្បីបញ្ចៀសការប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈជាក់ស្តែងប៉ុណ្ណោះ”[54]។

សហព្រះរាជអាជ្ញាលើកឡើងថា “ [...] ការលើកយករឿងក្តីរបស់តុលាការសិទ្ធិមនុស្សអឺរ៉ុបមកសំអាងនៅក្នុងបណ្តឹងនេះ មិនអាចយកមកអនុវត្តដោយរឹងត្អឹងហួសហេតុតាមបទដ្ឋានបែបនេះបានទេ។ តាមពិត ត្រូវពិចារណាថា ការរំខានដល់សណ្តាប់ធ្នាប់សាធារណៈអាចមានន័យជា “ការរំខាន់ដល់មតិសាធារណៈ”។ ទោះជាយ៉ាងណាក្តី ដូចដែលបានរៀបរាប់ខាងលើរួចមកហើយថា យុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប មិនអាចយកមកអនុវត្តដោយតឹងរ៉ឹងនៅក្នុងរឿងក្តីនៅតុលាការនេះបានទេដោយសារតែរឿងក្តីព្រហ្មទណ្ឌធម្មតានៅតុលាការសិទ្ធិមនុស្សអឺរ៉ុប មិនអាចយកមកធ្វើការប្រៀបធៀបក្នុងវិសាលភាពចំពោះរឿងក្តីឧក្រិដ្ឋសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នៅតុលាការនេះបានទេ។ [...] បទដ្ឋានសមស្របដែលគួរណែនាំដល់តុលាការនេះក្នុងការវាយតម្លៃអំពីការព្រួយបារម្ភទៅលើសណ្តាប់ធ្នាប់សាធារណៈ គឺត្រូវថ្លឹងថ្លែងពីផលប៉ះពាល់បណ្តាលមកពីការដោះលែង **អៀង សារី** ដែលអាចនឹងកើតមានដល់សណ្តាប់ធ្នាប់សាធារណៈក្នុងប្រទេសកម្ពុជា។ ផ្ទុយទៅនឹងអ្វីដែលបានអះអាងនៅក្នុងបណ្តឹងឧទ្ធរណ៍ គឺថាមានយុត្តិសាស្ត្រអន្តរជាតិបង្ហាញច្បាស់ថាវាមានទំនាក់ទំនងនឹងគ្នារវាងចលាចលផ្នែកសណ្តាប់ធ្នាប់សាធារណៈ និងការឃុំខ្លួនបណ្តោះអាសន្ន”[55]។

---

[53] កថាខណ្ឌទី៤៥ នៃសារណាតបរួមរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី ២០ ខែឧសភា ឆ្នាំ ២០០៨ ដែលឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់ **អៀង សារី** ចំពោះដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន។

[54] កថាខណ្ឌទី១១ នៃសារណាបណ្តឹងឧទ្ធរណ៍របស់ **អៀង សារី** ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៨ ចំពោះដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ។

[55] កថាខណ្ឌទី៥៦ និង៥៧ នៃសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី២៨ ខែ មករា ឆ្នាំ ២០០៨ ដែលឆ្លើយតបទៅនឹងសារណារបស់ **អៀង សារី** ចំពោះដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ។

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

00197705

C22 / I / 42



**៥) ការឃុំខ្លួនក្នុងផ្ទះ គឺជាជម្រើសជំនួសឲ្យការឃុំខ្លួនបណ្ដោះអាសន្ន**

សហមេធាវីការពារក្ដីលើកឡើងថា "ពេលអះអាងថា ពុំមានមូលហេតុដែលមិនគួរដោះលែងគាត់ឲ្យនៅក្រៅឃុំទេ លោក **អៀង សារី** សូមស្នើសុំដោយគោរពថា ដោយសារតែស្ថានភាពសុខភាពរបស់គាត់ ទម្រង់នៃការឃុំខ្លួនបណ្ដោះអាសន្នសមស្របជាងនេះ គឺការឃុំខ្លួនក្នុងផ្ទះ"[56]។

សហព្រះរាជអាជ្ញាលើកឡើងថា "ឯកសារជាមូលដ្ឋានរបស់តុលាការនេះ និងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាមិនបានលើកឡើងពីបញ្ហាការឃុំខ្លួនក្នុងផ្ទះទេ។ ប៉ុន្តែ នៅក្នុងរឿងក្ដី *Blaskic* តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី (ICTY) បានសម្រេចថា ការប្រើប្រាស់វិធានការការឃុំខ្លួនក្នុងផ្ទះជាជម្រើសជំនួសឲ្យការឃុំខ្លួនបណ្ដោះអាសន្ន គឺវាអាស្រ័យទៅលើទម្ងន់នៃកត្តាទាំងឡាយ ដូចជា:

1. មិនត្រូវមានភស្តុតាងថា ចុងចោទនឹងរត់គេចខ្លួនទេ
2. មិនត្រូវមានភវនីយភាពថា ចុងចោទនឹងធ្វើឲ្យប៉ះពាល់ដល់ភស្តុតាង និងសាក្សី
3. មិនត្រូវមានភវនីយភាពថា នឹងមានការបន្តនូវការប្រព្រឹត្តិឧក្រិដ្ឋកម្ម
4. និង មិនត្រូវមានការគំរាមកំហែងដល់សន្តិភាព និងសន្តិសុខ។

យោងតាមរឿងក្ដី *Blaskic* តុលាការអាចពិចារណាទៅលើការឃុំខ្លួនក្នុងផ្ទះ

1. ប្រសិនជាចុងចោទចាស់ជរា ឬមានជម្ងឺធ្ងន់ធ្ងរ
2. ប្រសិនជាការឃុំខ្លួននឹងមានហានិភ័យដល់អាយុជីវិតរបស់ចុងចោទ
3. ឬ ដើម្បីជារង្វាន់សម្រាប់ការប្រព្រឹត្តិល្អ"[57]។

**ខ- អង្គហេតុមានបញ្ហា**

**១) លក្ខខណ្ឌតម្រូវគតិយុត្តសម្រាប់ការឃុំខ្លួនបណ្ដោះអាសន្ន**

(ខ) <u>មូលហេតុដែលធ្វើឲ្យការឃុំខ្លួនបណ្ដោះអាសន្នក្លាយជាវិធានការចាំបាច់</u> (*វិធាន ៦៣-៣ (ខ)*)

*(១) មូលហេតុទី១ :*

*ដើម្បីរារាំងកុំឲ្យជនត្រូវចោទគាបសង្កត់ទៅលើសាក្សី ឬ ជនរងគ្រោះ ឬ រារាំងកុំឲ្យមានការត្រូវរូវគ្នារវាង*

---

[56] កថាខណ្ឌទី៤៤ នៃសារណាបណ្ដឹងឧទ្ធរណ៍របស់ **អៀង សារី** ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៨ ចំពោះដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ។

[57] កថាខណ្ឌទី៦៩ និង៧០ នៃសេចក្ដីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី២៨ ខែ មករា ឆ្នាំ ២០០៨ ដែលឆ្លើយតបទៅនឹងសារណាបណ្ដឹងឧទ្ធរណ៍របស់ **អៀង សារី** ចំពោះដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី ១៤ ខែវិច្ឆិកា ឆ្នាំ ២០០៧ ។

E.C.C.C. * C.E.T.C. * PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

*ជនត្រូវចោទនិងអ្នកសមគំនិតចំពោះបទឧក្រិដ្ឋដែលស្ថិតនៅក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ (វិធាន ៦៣-៣ (ខ) (១) នៃវិធានផ្ទៃក្នុង)*

សហមេធាវីការពារក្តីអះអាងថា “[...] វាធ្វើឲ្យនឹកឃើញថា នៅក្នុងរយៈពេលជាងដប់ឆ្នាំតាំងពីលោក **អៀង សារី** បានធ្វើសមាហរណកម្មជាមួយរាជរដ្ឋាភិបាលកម្ពុជាមក គាត់មិនដែលបានជេរប្រមាថមើលងាយ គំរាមកំហែង ឬវាយប្រហារលើសាក្សីសក្តានុពលណាម្តងឡើយ ទោះបីជាគាត់បានដឹងថា (ដូចមនុស្សគ្រប់រូបដទៃទៀតនៅក្នុងប្រទេសកម្ពុជាបានដឹងដែរ) ថា សហគមន៍ជាតិ និងអន្តរជាតិបានចូលរួមនៅក្នុងការបង្កើតតុលាការមួយដែលមានគោលបំណងកាត់ទោស យ៉ាងហោចណាស់ មេដឹកនាំខ្មែរក្រហមជាន់ខ្ពស់ដែលរងការចោទប្រកាន់នោះដែរ”[58]។

សហព្រះរាជអាជ្ញាអះអាងថា “សំណុំរឿងបានគាំទ្រចំពោះការសម្រេចរបស់សហចៅក្រមស៊ើបអង្កេត។ មុខនាទីជាន់ខ្ពស់ដែល **អៀង សារី** មាននៅក្នុងកំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ នៅក្នុងកំឡុងពេលនៃចលនានិរទេសនៅពេលក្រោយៗមកទៀតរបស់ខ្មែរក្រហម និងនៅក្នុងចលនានយោបាយនាពេលថ្មីៗបំផុតដទៃទៀតបង្ហាញឲ្យឃើញថា គាត់គឺជាមនុស្សមានអំណាច និងមានឥទ្ធិពលនៅកម្ពុជាសឹងតែពេញមួយជីវិតពេញវ័យគាត់ទៅហើយ។ រហូតមកដល់សព្វថ្ងៃនេះ គាត់ត្រូវបានគេរាយការណ៍ឲ្យដឹងថា គាត់នៅតែបន្តទទួលបានការគាំទ្រដ៏មានប្រជាប្រិយភាពនៅប៉ៃលិនដែលជា “តំបន់ក្បាលរឹងរបស់ខ្មែរក្រហម” ជាទំលាប់ហើយ ហើយនៅភ្នំពេញ និងនៅកន្លែងផ្សេងទៀត។ កូនប្រុសរបស់គាត់ឈ្មោះ **អៀង វុធ** គឺជាអភិបាលរងក្រុងប៉ៃលិន និងអតីតកងការពាររបស់គាត់ឈ្មោះ **អ៊ី ឈាន** គឺជាអភិបាលក្រុងនេះ។ សេចក្តីថ្លែងការណ៍ជាសាធារណៈរបស់ **អៀង វុធ** បង្ហាញពីអរិភាពរបស់ក្រុមគ្រួសារគាត់ ចំពោះគំនិតទាក់ទងនឹងការស្វែងរកយុត្តិធម៌ជូនជនរងគ្រោះដោយសាររបបខ្មែរក្រហម និងការកាត់ទោសក្រុមមេដឹកនាំជាន់ខ្ពស់នៃរបបនេះ ដូចជា ឪពុករបស់គាត់ជាដើម”[59]។ សហព្រះរាជអាជ្ញាបញ្ជាក់ទៀតថា “ផ្អែកលើការព្រួយបារម្ភពីការសងសឹង និងការបំភិតបំភ័យ សាក្សីមានសក្តានុពលមានការភ័យខ្លាចក្នុងការមកឆ្លើយបំភ្លឺនៅចំពោះមុខសាលាក្តីនេះ។ មន្ត្រីស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេតបានជួបប្រទះការលំបាកក្នុងការបំពេញបេសកកម្មប្រមូលភស្តុតាងរបស់ពួកគេ”[60]។

---

[58] កថាខណ្ឌទី៣០ នៃសារណាបណ្តឹងឧទ្ធរណ៍របស់ **អៀង សារី** ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៨ ចំពោះដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ។

[59] កថាខណ្ឌទី៣១ នៃសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី២៨ ខែ មករា ឆ្នាំ២០០៨ ដែលឆ្លើយតបទៅនឹងសារណាបណ្តឹងឧទ្ធរណ៍របស់ **អៀង សារី** ចំពោះដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧។

[60] កថាខណ្ឌទី៣២ នៃសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០០៨ ដែលឆ្លើយតបទៅនឹងសារណាបណ្តឹងឧទ្ធរណ៍របស់ **អៀង សារី** ចំពោះដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ។

E.C.C.C * C.E.T.C
PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE

មេធាវីដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា "ដោយសារជនត្រូវចោទមានសិទ្ធិពេញលេញក្នុងការមើលសំណុំរឿងដែលដឹងចម្លើយរបស់សាក្សី ព្រមទាំងឈ្មោះ និងអាសយដ្ឋានរបស់សាក្សី ដូច្នេះហានិភ័យមានការកើនឡើងខ្ពស់ដែលជននេះនឹងអាចប្រើប្រាស់ឥទ្ធិពលរបស់ខ្លួនឯងផ្ទាល់ ឬតាមរយៈរបស់អ្នកផ្សេងដើម្បីរារាំងសាក្សីទាំងនេះកុំឱ្យចូលមកឆ្លើយបំភ្លឺ។ លើសពីនេះទៀត ដូចដែលអង្គបុរេជំនុំជម្រះបានបង្ហាញហើយថា មានបរិយាកាសភ័យខ្លាចក្នុងការចូលមកផ្តល់សក្ខីភាព។ ឥទ្ធិពល និងអំណាចដ៏ទូលំទូលាយរបស់ជនត្រូវចោទនៅតែមានរហូតមកដល់សព្វថ្ងៃនេះ។ កាលៈទេសៈចូលសារភាពរបស់ជននេះនៅឆ្នាំ ១៩៩៦ និង ឥទ្ធិពលជាក់ស្តែងរបស់ជននេះមកលើកងកម្លាំងប្រដាប់អាវុធរបស់ពួកខ្មែរក្រហមបង្ហាញពីអំណាចរបស់ជននេះ។ សកម្មភាព ដូចជាការមកទស្សនកិច្ចក្រុងប៉ៃលិនជាញឹកញាប់ដើម្បីជួបប្រជុំជាមួយមន្ត្រីរដ្ឋាភិបាលចំនួន៣០នាក់ ដើម្បីប្រាប់ពួកគេកុំអោយពាក់ព័ន្ធនឹងចលនាប្រដាប់អាវុធ គឺជាសកម្មភាពបង្ហាញពីអំណាចរបស់ជននេះ"[61]។

*(២) មូលហេតុទី២ :*

*ដើម្បីថែរក្សាភស្តុតាង ឬការពារមិនឱ្យបំផ្លាញភស្តុតាង (វិធាន ៦៣-៣ (ខ) (២) នៃវិធានផ្ទៃក្នុង)*

សហមេធាវីការពារក្តីពុំបានលើឡើងណាមួយទាក់ទងនឹងមូលហេតុនេះទេ។

សហព្រះរាជអាជ្ញាបានលើកឡើងថា "នៅក្នុងករណីរបស់ **ឌុច** អង្គបុរេជំនុំជម្រះបានទទួលស្គាល់ថា កំណត់ហេតុបំភ្លឺរបស់សាក្សីអំពីព្រឹត្តិការណ៍នៃបទឧក្រិដ្ឋដែលចុងចោទត្រូវបានចោទប្រកាន់គឺជា"ភស្តុតាង" ស្របតាមខ្លឹមសារនៃវិធាន ៦៣-៣ (ខ)(២) នៃវិធានផ្ទៃក្នុង។ ហេតុដូច្នេះ ការជ្រៀតជ្រែកសាក្សី ដូចបានអះអាងខាងលើអាចជាការដកហូតភស្តុតាងពាក់ព័ន្ធ ចេញពីតុលាការដែលកំពុងដំណើរការ"[62]។

*(៣) មូលហេតុទី៣ :*

*ដើម្បីធានាពីវត្តមានរបស់ជនត្រូវចោទនៅក្នុងដំណើរការនីតិវិធី(វិធាន ៦៣-៣ (ខ) (៣) នៃវិធានផ្ទៃក្នុង*

សហមេធាវីការពារក្តីលើកសំអាងថា " [...] វាមានការដឹងឮជាទូទៅនៅពាសពេញប្រទេសកម្ពុជាថា សហគមន៍ជាតិ និងអន្តរជាតិបានចូលរួមចំណែកបង្កើតតុលាការមួយក្នុងគោលបំណងកាត់ទោសយ៉ាងហោចណាស់ក្រុមមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមដែលរងការចោទប្រកាន់។ វាក៏ត្រូវបានដឹងឮជាទូទៅផងដែរថា **តាម៉ុក** ក៏ដូចជា **កាំង ហ្កេកអ៊ាវ** (ហៅ "**ឌុច**") បានស្ថិតនៅក្នុងការឃុំឃាំងអស់រយៈពេលជាច្រើនឆ្នាំ ខណៈពេល

---

[61] កថាខណ្ឌទី៤៧ នៃសារណាតបរួមរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០០៨ ដែលឆ្លើយតបទៅនឹងសារណាបណ្តឹងឧទ្ធរណ៍របស់ **អៀង សារី** ចំពោះដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន។

[62] កថាខណ្ឌទី៣៥ នៃសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០០៨ ដែលឆ្លើយតបទៅនឹងសារណាបណ្តឹងឧទ្ធរណ៍របស់ **អៀង សារី** ចំពោះដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

រង់ចាំងការបង្កើតឡើងនូវអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការនេះ។ គ្មានអ្វីគួរឆ្ងល់ទេថា លោក **អៀង សារី** ក៏បានដឹងរឿងហេតុទាំងនេះដែរ។ ដោយជំទាស់នឹងព្រឹត្តិការណ៍នៅពីក្រោយរឿងនេះ ប្រសិនបើសំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេតមានទម្ងន់គួរឱ្យជឿបាន ដូច្នេះអាចសន្មតបានថា ភស្តុតាងចង្អុលបង្ហាញមួយចំនួនត្រូវតែមាន ទោះបីបន្តិចបន្តួចក៏ដោយ ដើម្បីបង្ហាញថា លោក **អៀង សារី** បានប្រើប្រាស់ដោយខ្លួនគាត់នូវទ្រព្យសម្បត្តិ មិត្តភ័ក្តបរទេស និងលិខិតឆ្លងដែនដែលសន្មតថាគាត់មាននោះ ដើម្បីចាកចេញពីប្រទេសកម្ពុជា និង/ឬលាក់បំពួនអាត្មា ជាពិសេស ក្រោយពេលបង្កើតឡើងនូវអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការដែលមានការផ្សព្វផ្សាយដឹងឮជាសាធារណៈយ៉ាងច្រើនបែបនេះ។ ការិយាល័យសហព្រះរាជអាជ្ញាពុំបានផ្តល់ភស្តុតាងណាមួយ ហើយសហចៅក្រមស៊ើបអង្កេតក៏ពុំបានពឹងអាស្រ័យលើភស្តុតាងណាមួយឡើយ ដោយហេតុថាគ្មានភស្តុតាងបែបនោះទេ”[63]។

សហព្រះរាជអាជ្ញាលើកសំអាងថា “[...]**អៀង សារី** មានមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការគេចខ្លួនរបស់ខ្លួន ហើយស្នាក់នៅក្នុងប្រទេសមួយផ្សេងទៀត នៅកន្លែងណាមួយលើពិភពលោក។ ជននេះមានមិត្តភ័ក្តច្រើននៅបរទេសដែលធ្លាប់ជួយគាត់កាលពីពេលកន្លងមកក្នុងការធ្វើដំណើរទៅបរទេស និងមានលទ្ធភាពធ្វើដូច្នេះទៀតនាពេលអនាគត។ ក្នុងនាមជារដ្ឋមន្ត្រីក្រសួងការបរទេសនៃកម្ពុជាប្រជាធិបតេយ្យ **អៀង សារី** មានការទាក់ទងជាទៀតទាត់ជាមួយមន្ត្រីចិន ហើយក្រោយការដួលរលំនៃរបបនេះ **អៀង សារី** នៅបន្តមានទំនាក់ទំនងបែបនេះទៀត។ នេះអាចជាហេតុផលដែលលិខិតឆ្លងដែនផ្លូវការចិនចេញអោយជននេះនៅថ្ងៃទី ២៧ ខែមករា ឆ្នាំ ១៩៧៩ ដោយក្រសួងការបរទេសចិន។ លិខិតឆ្លងដែនមានបិទរូបថតជននេះ និងដាក់ឈ្មោះថា “ស៊ូ ហោ” ដែលតាមព្រះរាជអាជ្ញាយល់ថាជាឈ្មោះមួយក្នុងចំណោមឈ្មោះបដិវត្តរបស់ជននេះ។ ដើម្បីលាក់កំបាំងអត្តសញ្ញាណរបស់ខ្លួនឱ្យបានល្អ **អៀង សារី** ផ្តល់ទីកន្លែងកំណើតរបស់ខ្លួនថានៅ ប៉េកាំង។ នេះមិនមែនជាលើកទីមួយដែលជននេះក្លែងបន្លំទីកន្លែងកំណើតរបស់ខ្លួនឡើយ។ ពេលចូលបង្ហាញខ្លួនជាលើកដំបូង ជននេះបានប្រាប់សហចៅក្រមស៊ើបអង្កេតថា ខ្លួនធ្លាប់បានធ្វើដូច្នេះពីមុនមកផងដែរ ទាក់ទងនឹងថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើតរបស់ខ្លួន”[64]។

សហព្រះរាជអាជ្ញាលើកសំអាងបន្ថែមទៀតថា “**អៀង សារី** ធ្លាប់ធ្វើសេចក្តីថ្លែងការណ៍ដោយមិនច្បាស់លាស់ជាសាធារណៈទាក់ទងនឹងការចូលរួមរបស់ខ្លួននៅក្នុងដំណើរការរបស់តុលាការ [...] ។ លើសពីនេះ ដោយហេតុថាឥឡូវនេះ ជននេះបានចាប់ខ្លួនហើយ ហើយគ្មានការការពារពីការអនុគ្រោះទោសរបស់ខ្លួនទៀតនោះ “ប្រ

---

[63] កថាខណ្ឌទី ៣៥ នៃសារណាបណ្តឹងឧទ្ធរណ៍របស់ **អៀង សារី** ចុះថ្ងៃទី ១៥ ខែ មករាឆ្នាំ ២០០៨ ចំពោះដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧។

[64] កថាខណ្ឌទី៣៩ នៃសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០០៨ ដែលឆ្លើយតបទៅនឹងសារណាបណ្តឹងឧទ្ធរណ៍របស់ **អៀង សារី** ចំពោះដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧។

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE ECCC CETC

ការដែលជននេះនឹងទទួលការជំនុំជម្រះជាសាធារណៈនៅចំពោះមុខអតីតជនរងគ្រោះរបស់ខ្លួនពីបទល្មើសដែលខ្លួនកំពុងទទួលបានការចោទប្រកាន់ អាចផ្តល់ជាការលើកទឹកចិត្តបន្ថែមទៀតឱ្យជននេះរត់គេចខ្លួន””[65]។

មេធាវីដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងថា “ការគាំទ្រដល់ជនត្រូវចោទនៅក្រុងប៉ៃលិន ការកាន់លិខិតឆ្លងដែន និងការដាក់ពន្ធនាគារអស់មួយជីវិត ប្រសិនបើខ្លួនទទួលការផ្តន្ទាទោស គឺជាហេតុផលសមស្របដែលត្រូវពិចារណាពីហានិភ័យនៃការរត់គេចខ្លួន។ ការលើកសំអាងថា ជនត្រូវចោទមិនបានគេចខ្លួនទេ ទោះបីខ្លួនបានដឹងពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាក៏ដោយនោះ មិនអាចទទួលយកបានឡើយ។ ជនត្រូវចោទដែលទទួលបានព្រះរាជទានការអនុគ្រោះទោស និងការលើកលែងទោសពីព្រះមហាក្សត្រ ព្រមទាំងទទួលបានការគាំទ្រពីប្រមុខរដ្ឋាភិបាលដែលធ្លាប់បានធ្វើអត្ថាធិប្បាយថា **អៀង សារី** នឹងមិនទទួលបានការជំនុំជម្រះក្តីទេ ដោយសារតែគាត់បានដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តួចផ្តើមបង្កើតសន្តិភាព និងការបង្រួបបង្រួមជាតិ។ ស្ថិតក្នុងកាលៈទេសៈទាំងនេះ គេមិនរំពឹងថាមានការឃុំខ្លួនជនត្រូវចោទឡើយ”[66]។

*(៤) មូលហេតុទី៤:*

*ដើម្បីការពារសន្តិសុខឱ្យជនត្រូវចោទ (វិធាន ៦៣-៣ (ខ) (៤) នៃវិធានផ្ទៃក្នុង)*

សហមេធាវីការពារក្តីលើកឡើងថា “សន្តិសុខរបស់លោក **អៀង សារី** មិនមែនជាហេតុផលត្រឹមត្រូវដើម្បីឃុំខ្លួនគាត់ទេ ជាពិសេសនៅពេលដែល [...] ស្ថានភាពនៃការឃុំខ្លួនបច្ចុប្បន្នធ្វើឱ្យគាត់មានគ្រោះថ្នាក់យ៉ាងខ្លាំង (ប្រសិនបើមិនបណ្តាលឱ្យស្លាប់) ដល់ស្ថានភាពសុខភាពផុយស្រួយរបស់លោក **អៀង សារី** ”[67]។

សហមេធាវីការពារក្តីលើកឡើងថា “លោក **អៀង សារី** បានរស់នៅដោយសេរី និងចំហនៅកណ្តាលក្រុងភ្នំពេញអស់ពេលជិតមួយទសវត្ស។ ពេលវេលាពេញនៅក្នុងរយៈពេលនេះ មានការដឹងឮជាទូទៅហើយថាលោក **អៀង សារី** មានជាប់ពាក់ព័ន្ធជាមួយ និងជាផ្នែកមួយនៃអតីតមេដឹកនាំជាន់ខ្ពស់របស់ខ្មែរក្រហម ហើយគាត់បានរស់នៅក្នុងក្រុងភ្នំពេញ។ ទីតាំងលំនៅដ្ឋានរបស់គាត់ត្រូវបានគេស្គាល់យ៉ាងច្បាស់។ គ្មានកម្លាំងសន្តិសុខទោះប្រដាប់ដោយអាវុធ ឬគ្មានអាវុធក្តី ត្រូវបានជួលឱ្យមើលលំនៅដ្ឋានរបស់គាត់ ឱ្យការពារសន្តិសុខរូបគាត់ ឬសមាជិកគ្រួសារដែលរស់នៅជាមួយគាត់នោះទេ។ លោក **អៀង សារី** បានរស់នៅក្នុងជីវិតសាមញ្ញនៅក្នុងលំនៅដ្ឋានមួយដែលគ្មានលេនដ្ឋានការពារ គ្មានរបងបន្លាលួស និងគ្មានរបងដាក់ចរន្តអគ្គិសនីឱ្យឆក់ទេ។ ជាការពិត

---

[65] កថាខណ្ឌទី៤០ នៃសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០០៨ ដែលឆ្លើយតបទៅនឹងសារណាបណ្តឹងឧទ្ធរណ៍របស់ **អៀង សារី** ចំពោះដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ។

[66] កថាខណ្ឌទី៤៧ នៃសារណាគបរួមរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០០៨ ដែលឆ្លើយតបទៅនឹងសារណាបណ្តឹងឧទ្ធរណ៍របស់ **អៀង សារី** ចំពោះដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន។

[67] កថាខណ្ឌទី២៣ នៃសារណាបណ្តឹងឧទ្ធរណ៍របស់ **អៀង សារី** ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៨ ចំពោះដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧។

E.C.C.C. * C.E.T.C. PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

ណាស់ លោក **អៀង សារី** មិនដែលរងការជេរប្រមាថមើលងាយ ការគំរាមកំហែង ឬការវាយប្រហារម្តងណាទេនៅក្នុងរយៈពេលជាង១០ឆ្នាំកន្លងមកនេះ តាំងពីបានធ្វើសមាហរណកម្មជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជាមក[68]"។

សហមេធាវីការពារក្តីគូសបញ្ជាក់ថា "សហចៅក្រមស៊ើបអង្កេតបានកត់សំគាល់ជាថ្មីម្តងទៀត ដោយមិនបានផ្តល់នូវមូលដ្ឋានអង្គហេតុ ឬភស្តុតាងដើម្បីគាំទ្រការអះអាងរបស់ខ្លួនឡើយ ដោយកត់សំគាល់ថា "ច្បាស់ណាស់ថា ស្ថានការណ៍ត្រូវបានគេដឹងក្នុងលក្ខណៈមិនដូចគ្នាទៀតឡើយ ចាប់តាំពីមានការចោទប្រកាន់ជាផ្លូវការរួចមក"។ ចំណុចនេះហាក់ដូចជាមិនទំនងទាល់តែសោះ។ ក្រុមអ្នកធ្វើអត្ថាធិប្បាយ និងអ្នកសារព័ត៌មានបានចោទប្រកាន់លោក **អៀង សារី** យូរមកហើយ ថាមានជាប់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ថាបានប្រព្រឹត្តក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ទាំងប្រជាពលរដ្ឋកម្ពុជាសាមញ្ញធម្មតា ទាំងអ្នកប្រាជ្ញអន្តរជាតិហាក់ដូចជាសន្មតថាគាត់មានពិរុទ្ធ។ ជាការពិតណាស់ វាមិនមែនជាការបំផ្លើសសំដីក្នុងការកត់សំគាល់ឃើញថា នៅក្នុងមតិរបស់សាធារណជន ដែលត្រូវបានដុតបញ្ឆេះអស់រយៈពេលជាច្រើនឆ្នាំមកហើយដោយសេចក្តីថ្លែងការណ៍ សេចក្តីប្រកាសព័ត៌មាន និងអត្ថបទអក្សរសាស្ត្រពី "អ្នកជំនាញការ" កម្ពុជាច្រើននាក់ (រួមទាំងអ្នកដែលកំពុងបំរើការងារនៅការិយាល័យសហព្រះរាជអាជ្ញានិងការិយាល័យសហចៅក្រមស៊ើបអង្កេតផងដែរ) វាជាសេចក្តីសន្និដ្ឋានមួយដែលថា សមាជិកជាន់ខ្ពស់ទាំងអស់របស់ខ្មែរក្រហមមានពិរុទ្ធ។ ដូច្នេះ ការលើកឡើងថាស្ថានការណ៍មានលក្ខណៈមិនដូចគ្នា ដោយសារតែមានការចោទប្រកាន់ជាផ្លូវការនោះ វាផ្ទុយពីការពិត និងសុភវិនិច្ឆ័យ"[69]។

សហព្រះរាជអាជ្ញាអះអាងថា "ការកើនឡើងនូវហានិភ័យអំពី "ការវាយប្រហារដើម្បីសងសឹង" ត្រូវបានបង្ហាញភស្តុតាងដោយមកពីអង្គហេតុថា ជនរងគ្រោះទាំងឡាយកាលពីក្នុងពេលសវនាការសាធារណៈលើកដំបូងកាលពីថ្ងៃទី ២០-២១ ខែវិច្ឆិកា ឆ្នាំ ២០០៧ ត្រូវបានគេរាយការណ៍មកថា បានជួបប្រទះការលំបាកក្នុងការអត់ធ្មត់ពីការប្រព្រឹត្តិអំពើហិង្សាដែលអាចកើតឡើងដោយឯកឯង នៅពេលឃើញប្រធានមន្ទីរឃុំឃាំងស-២១ ដែលមានកេរ្តិ៍ឈ្មោះមិនល្អឋិតនៅក្នុងចម្ងាយជិតបែបនេះ។ ដោយពិចារណាទៅលើឋានៈ និងតួនាទីដ៏សំខាន់របស់ **អៀង សារី** ក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មនៅក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ ទំនងជាអាចមានអំពើហិង្សាជាច្រើនដែលសំដៅទៅលើរូបគាត់ បើសិនជាដោះលែងគាត់ ឬដាក់គាត់ឲ្យឋិតនៅក្នុងការឃុំឃាំងក្នុងផ្ទះក្នុង

---

[68] កថាខណ្ឌទី២៤ នៃសារណាបណ្តឹងឧទ្ធរណ៍របស់ **អៀង សារី** ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៨ ចំពោះដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧។

[69] កថាខណ្ឌទី២៥ នៃសារណាបណ្តឹងឧទ្ធរណ៍របស់ **អៀង សារី** ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៨ ចំពោះដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧។

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

ចំណោមប្រជាជនទូទៅ"[70]។

សហព្រះរាជអាជ្ញាបានអះអាងទៀតថា "[...]ជាច្រើនលើកច្រើនគ្រា **អៀង សារី** បានឆ្លើយដាក់មេដឹកនាំជាន់ខ្ពស់ដទៃទៀតនៃរបបនោះដែលរួមមានមេដឹកនាំជាន់ខ្ពស់ដែលកំពុងត្រូវបានចោទប្រកាន់ ឬដែលទំនងជានឹងត្រូវចោទប្រកាន់នៅចំពោះមុខតុលាការនេះផង។ ប្រការនេះជាការជាក់ច្បាស់ណាស់ថា វានឹងបង្កឱ្យមានគ្រោះថ្នាក់ដល់ចំពោះជីវិតគាត់ ដែលអាចនឹងបណ្តាលមកពីអ្នកដែលមិនចង់ឃើញការកាត់ទោសតាមអាណត្តិរបស់តុលាការនេះមានដំណើរការដោយជោគជ័យ"[71]។

មេធាវីដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងថា "អង្គបុរេជំនុំជម្រះបានកត់សំគាល់យ៉ាងត្រឹមត្រូវនៅក្នុងសាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍ **នួន ជា** ថា នេះជាផលប្រយោជន៍ដ៏ធំធេងនៅក្នុងសវនាការ សាធារណជនអាចមានប្រតិកម្មខឹងសម្បារលើ **ឌុច** ហើយ វាអាចមានផលប៉ះពាល់យ៉ាងណាខ្លះដល់សង្គមកម្ពុជា ប្រសិនបើដោះលែងជនត្រូវចោទរូបនេះ (ឬជនត្រូវចោទផ្សេងទៀត)"[72]។

*(៥)មូលហេតុទី៥:*

*ដើម្បីរក្សាសណ្តាប់ធ្នាប់សាធារណៈ (វិធាន ៦៣-៣ (ខ) (៥) នៃវិធានផ្ទៃក្នុង)*

សហមេធាវីការពារក្តីលើកឡើងថា"ពុំមានភស្តុតាងគួរឱ្យជឿទុកចិត្តដើម្បីសន្និដ្ឋានថា ការដោះលែង **អៀង សារី** ឱ្យនៅក្រៅឃុំបណ្តោះអាសន្នរង់ចាំសវនាការនឹងប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈនោះទេ"[73]។ សហមេធាវីការពារក្តីបញ្ជាក់ថា " ជាការប្រពៃណាស់ដែលធ្វើឱ្យនឹកឃើញថា គ្មានការតវ៉ាពីការមិនពេញចិត្តដែលអាចបង្កឱ្យមានអំពើហិង្សា ដោយប្រៀបធៀបទៅនឹងបរិបទផុយស្រួយនៃសង្គមកម្ពុជានាពេលអតីតកាល នៅពេល **អៀង សារី** វិលត្រឡប់ចូលសង្គមជាតិវិញ បន្ទាប់ពីមានការប្រកាសពីព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោសឱ្យគាត់ នៅឆ្នាំ ១៩៩៦"[74]។

---

[70] កថាខណ្ឌទី៤៦ នៃសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០០៨ ដែលឆ្លើយតបទៅនឹងសារណាបណ្តឹងឧទ្ធរណ៍របស់ **អៀង សារី** ចំពោះដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧។

[71] កថាខណ្ឌទី៤៨ នៃសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០០៨ ដែលឆ្លើយតបទៅនឹងសារណាបណ្តឹងឧទ្ធរណ៍របស់ **អៀង សារី** ចំពោះដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧។

[72] កថាខណ្ឌទី៤៦ នៃសារណាតបរួមរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០០៨ ដែលឆ្លើយតបទៅនឹងសារណាបណ្តឹងឧទ្ធរណ៍របស់ **អៀង សារី** ចំពោះដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន។

[73] កថាខណ្ឌទី៧ នៃសារណាបណ្តឹងឧទ្ធរណ៍របស់ **អៀង សារី** ចុះថ្ងៃទី ១៥ ខែ មករាឆ្នាំ ២០០៨ ចំពោះដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧។

[74] កថាខណ្ឌទី១០ នៃសារណាបណ្តឹងឧទ្ធរណ៍របស់ **អៀង សារី** ចុះថ្ងៃទី ១៥ ខែ មករាឆ្នាំ ២០០៨ ចំពោះដីកាសម្រេចឃុំខ្លួនបណ្តោះ

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C.

សហមេធាវីការពារក្តីលើកឡើងបន្ថែមទៀតថា“ពុំមានភស្តុងតាងដើម្បីគាំទ្រការអះអាងណាមួយដែលថា សង្គមកម្ពុជាស្ថិតក្នុងស្ថានភាពផុយស្រួយ ហើយត្រូវទទួលខុសត្រូវក្នុងការផ្ទុះនូវការតវ៉ាដោយមានអំពើហិង្សា។ ការិយាល័យសហព្រះរាជអាជ្ញាបានលើកឡើងជាភស្តុតាងអំពីកុប្បកម្មប្រឆាំងនឹងថៃកាលពីឆ្នាំ ២០០៣ ថា សង្គមកម្ពុជាជាសង្គមមួយគ្មានស្ថិរភាព គឺមិនអាចជឿបានទេ។ មានឧទាហរណ៍ដោយឡែលផ្សេងទៀតអំពីការរំខានដល់សណ្តាប់ធ្នាប់សាធារណៈដែលមិនចាំបាច់គិតថា វាធ្វើឲ្យសង្គមមួយ ‘ផុយស្រួយ’ ឬ គ្មានស្ថិរភាពឡើយ”[75]។

សហមេធាវីការពារក្តីលើកឡើងថា “វានៅតែអថិកំបាំងដដែលដែលថាតើសហចៅក្រមស៊ើបអង្កេតបានកំណត់ថាឧក្រិដ្ឋកម្មដែលបានចោទប្រកាន់នោះ “នៅតែជាបញ្ហាប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ” យ៉ាងណានោះទេ។ [...] សូមជម្រាបអង្គបុរេជំនុំជម្រះដោយក្តីគោរពថា រូបភាពនៃសង្គមកម្ពុជា គឺខុសគ្នាខ្លាំងណាស់ពីអ្វីដែលត្រូវបានលាបពណ៌ដោយការិយាល័យសហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេត។ ប្រភពរបស់រដ្ឋាភិបាល ក៏ដូចជាភ្នាក់ងារអន្តរជាតិឯករាជ្យនានាទទួលស្គាល់ថា កម្ពុជាបច្ចុប្បន្នគឺជាប្រទេសមានសន្តិភាព និងស្ថិរភាព។ [...] ការលើកឡើងថា សង្គមកម្ពុជាមានភាពផុយស្រួយខ្លាំងដែលអាចនាំឲ្យមានអំពើហិង្សា ប្រសិនបើតុលាការអនុញ្ញាតឲ្យមានការដោះលែងបណ្តោះអាសន្នដល់ជនដែលត្រូវបានសន្មតជាមុនថាគ្មានទោស គឺជាការមើលងាយដល់ភាពចាស់ទុំដល់សង្គមកម្ពុជា និងជោគជ័យរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការនាំមកនូវសន្តិភាព និងស្ថិរភាព”[76]។

សហព្រះរាជអាជ្ញាអះអាងថា “ដំណើរការនីតិវិធីអាចនឹងបង្កបណ្តាលឲ្យមានហានិភ័យដល់សង្គមកម្ពុជា តាមរយៈការលេចចេញជាថ្មីនូវការព្រួយបារម្ភ និងផលវិបាលជាអវិជ្ជមានក្នុងសង្គមខាងលើ”[77]។

សហព្រះរាជអាជ្ញាអះអាងបន្ថែមទៀតថា “ស្ថានភាពបច្ចុប្បន្នរបស់ប្រទេសកម្ពុជា [...]គឺមិនអាចធ្វើការប្រៀបធៀបគ្នាទៅនឹងស្ថានភាពកាលពីឆ្នាំ ១៩៩៦ បានទេ ។ [...] ការដោះលែង **អៀង សារី** និងការប៉ះពាល់ដោយសារការដោះលែងនេះចំពោះសណ្តាប់ធ្នាប់សាធារណៈមិនអាចធ្វើការប៉ាន់ប្រមាណដោយគ្រាន់តែផ្អែកទៅលើព្រឹត្តិការណ៍កន្លងមកតែមួយគត់ប៉ុណ្ណោះបានទេ”[78]។

---

អាសន្ន ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧។

[75] កថាខណ្ឌទី១២ នៃសារណាបណ្តឹងឧទ្ធរណ៍របស់ **អៀង សារី** ចុះថ្ងៃទី ១៥ ខែ មករាឆ្នាំ ២០០៨ ចំពោះដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧។

[76] កថាខណ្ឌទី១៥, ១៦ និង២០ នៃសារណាបណ្តឹងឧទ្ធរណ៍របស់ **អៀង សារី** ចុះថ្ងៃទី ១៥ ខែ មករាឆ្នាំ ២០០៨ ចំពោះដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧។

[77] កថាខណ្ឌទី៥០ នៃសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០០៨ ដែលឆ្លើយតបទៅនឹងសារណាបណ្តឹងឧទ្ធរណ៍របស់ **អៀង សារី** ចំពោះដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧។

[78] កថាខណ្ឌទី៥១ នៃសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០០៨ ដែលឆ្លើយតបទៅនឹងសារណាបណ្តឹង

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C.

សហព្រះរាជអាជ្ញាគូសបញ្ជាក់ថា “**អៀង សារី** ផ្អែកទៅលើសុន្ទរកថារបស់នាយករដ្ឋមន្ត្រីនៃប្រទេសកម្ពុជា និងរបាយការណ៍មួយចំនួនតូចផ្សេងទៀតដើម្បីយកមកប្រកែកតវ៉ាថា កម្ពុជាគឺជាប្រទេសមួយដែលមាន “សន្តិភាព និងស្ថិរភាព” ដូច្នេះហើយ មានន័យថា ការឃុំខ្លួនដោយផ្អែកលើ សណ្តាប់ធ្នាប់សាធារណៈ មិនគួរគាំទ្រទេ។ [...] គាត់មិនបានដាក់ឯកសារទាំងនេះនោះទេ។ បើសិនជាឯកសារទាំងនោះជាឯកសារដែលសហព្រះរាជអាជ្ញាជឿថា គឺជាឯកសារដែលគាត់កំពុងយោងពិតមែននោះ គឺវាច្បាស់លាស់ថា គាត់បានស្រង់ខ្លឹមសារដោយជម្រើស ហើយស្ថិតនៅក្រៅបរិបទដែលកំពុងពិភាក្សាទៀតផង។ សុន្ទរកថា និងរបាយការណ៍ទាក់ទងស្ទើរតែទាំងស្រុងទៅនឹងបញ្ហាសេដ្ឋកិច្ច ហើយត្រូវតែមើលឃើញទៅតាមនោះដែរ”[79]។ “ ខណៈពេលដែលប្រទេសកម្ពុជាបានជួបប្រទះការរីកចម្រើនផ្នែកសេដ្ឋកិច្ចនៅក្នុងកន្លងពេលថ្មីៗនេះក៏ដោយ សភាពការណ៍សន្តិសុខនៅក្នុងប្រទេសកម្ពុជានៅតែមានបញ្ហាខ្លាំងដែលដោសារសមត្ថភាពក្នុងការប្រតិបត្តិច្បាប់នៅទាន់ខ្សោយ”[80]។

មេធាវីដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងថា “បទពិសោធន៍ប្រចាំថ្ងៃ ឧទាហរណ៍ដូចជា មុននឹងមានការបោះឆ្នោតនៅខែកក្កដាខាងមុខនេះ បង្ហាញពីបរិយាកាសតានតឹងនៅក្នុងសង្គម។ [...] អាចសន្និដ្ឋានបានថា និងគួរតែជាមានការយល់ដឹងទូទៅថា សង្គមកម្ពុជាគឺនៅតែមានភាពផុយស្រួយនៅឡើយ”[81]។

---

ឧទ្ធរណ៍របស់ **អៀង សារី** ចំពោះដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧។

[79] កថាខណ្ឌទី៥២ នៃសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០០៨ ដែលឆ្លើយតបទៅនឹងសារណាបណ្តឹងឧទ្ធរណ៍របស់ **អៀង សារី** ចំពោះដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧។

[80] កថាខណ្ឌទី៥៤ នៃសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០០៨ ដែលឆ្លើយតបទៅនឹងសារណាបណ្តឹងឧទ្ធរណ៍របស់ **អៀង សារី** ចំពោះដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧។

[81] កថាខណ្ឌទី៤៦ នៃសារណាតបរួមរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០០៨ ដែលឆ្លើយតបទៅនឹងសារណាបណ្តឹងឧទ្ធរណ៍របស់ **អៀង សារី** ចំពោះដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន។

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

## ២) ការកែប្រែលក្ខខណ្ឌឃុំខ្លួនបច្ចុប្បន្នទៅជាលក្ខខណ្ឌឃុំខ្លួនក្នុងផ្ទះវិញ

សហមេធាវីការពារក្តីលើកឡើងថា "ទោះបីជាក្នុងសង្គមដែលពិតជាផុយស្រួយ តុលាការអន្តរជាតិបានដោះលែងឲ្យនៅក្រៅឃុំបណ្តោះអាសន្នដល់ជនដែលត្រូវបានចោទប្រកាន់ពីបទរំលោភលើច្បាប់មនុស្សធម៌"[82]។

សហមេធាវីការពារក្តីលើកឡើងទៀតថា "ប្រសិនបើជាការពិត ការសាកល្បងដោះលែងឲ្យនៅក្រៅឃុំបណ្តោះអាសន្នដែលថាជនជាប់ចោទត្រូវបានរួចផុតពីអំណាច និងឥទ្ធិពលពិតប្រាកដមែន ឬដែលមានការដឹងឮចុះហេតុអ្វីបានជនជាប់ចោទដែលមានឥទ្ធិពល និងអំណាចប្រកបដោយសក្តានុពលមួយចំនួនធំ ត្រូវបានដោះលែងឲ្យនៅក្រៅឃុំបណ្តោះអាសន្ននៅតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី មិនមែនត្រឹមតែស្ថិតក្នុងដំណាក់មុនអង្គសេចក្តីនោះទេ តែថែមទាំងនៅពេលវិស្សមកាលនៅរដូវត្រជាក់ និងនៅរដូវក្តៅនៅក្នុងដំណាក់ជំនុំជម្រះអង្គសេចក្តីបានទៀតផង។ ប្រការនេះអាចត្រៀមទុកមើលឃើញជាស្រេចតាមរយៈឧទាហរណ៍លើកឡើងនៅក្នុងឧបសម្ព័ន្ធ ក"[83]។

សហមេធាវីការពារក្តីបញ្ជាក់ថា "នៅពេលដែលហានិភ័យរត់គេចខ្លួនគឺជាមូលហេតុស្របច្បាប់តែមួយគត់សម្រាប់ការឃុំខ្លួនបណ្តោះអាសន្ន នោះតុលាការគួរចេញដីកាសម្រេចដោះលែងឲ្យក្រៅឃុំជាបណ្តោះអាសន្នរង់ចាំការជំនុំជម្រះដល់អង្គសេចក្តី ប្រសិនបើទទួលបានការធានាពីជនត្រូវចោទថា ជននេះនឹងមានវត្តមានក្នុងពេលសវនាការ។ យើងខ្ញុំស្នើសុំដោយក្តីគោរពថា ការធានាបែបនេះត្រូវតែទទួលការគាំទ្រ និងទទួលយកពេលណាមានការគាំទ្រដោយការធានាបន្ថែមពីអាជ្ញាធរមានសមត្ថកិច្ចស្របច្បាប់ ដូចជានគរបាលមូលដ្ឋាន ដូចនៅក្នុងរឿងក្តីនេះមានការយល់ព្រមពីរាជរដ្ឋាភិបាលកម្ពុជា"[84]។

សហមេធាវីការពារក្តីលើកឡើងថា " ការឃុំខ្លួនក្នុងផ្ទះត្រូវបានគេយល់ឃើញថា ជាទំរង់នៃការត្រួតពិនិត្យតាមផ្លូវតុលាការ។ [...] អង្គបុរេជំនុំជម្រះគួរពិនិត្យឡើងវិញនូវជម្រើសនៃការឃុំខ្លួនផ្សេងដែលគេស្គាល់យ៉ាងទូលំទូលាយ បានបង្ហាញឲ្យឃើញថាបានជោគជ័យបំផុតក្នុងរឿងក្តី **ប៊ីលចាណា ភ្លាវស៊ីក** (Biljana Plavsic ) នៅតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី។ [...] ការណ៍ដែលលើកឡើកថា រាជរដ្ឋាភិបាលកម្ពុជាពុំមានសមត្ថភាពផ្តល់សន្តិសុខដល់ **អៀង សារី** ឬ ដឹកជញ្ជូនគាត់ដោយសុវត្ថិភាពទៅកាន់អង្គជំនុំជម្រះ

[82] កថាខណ្ឌទី១៤ នៃសារណាបណ្តឹងឧទ្ធរណ៍របស់ **អៀង សារី** ចុះថ្ងៃទី ១៥ ខែ មករាឆ្នាំ ២០០៨ ចំពោះដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧។

[83] កថាខណ្ឌទី២៩ នៃសារណាបណ្តឹងឧទ្ធរណ៍របស់ **អៀង សារី** ចុះថ្ងៃទី ១៥ ខែ មករាឆ្នាំ ២០០៨ ចំពោះដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧។

[84] កថាខណ្ឌទី៣៤ នៃសារណាបណ្តឹងឧទ្ធរណ៍របស់ **អៀង សារី** ចុះថ្ងៃទី ១៥ ខែ មករាឆ្នាំ ២០០៨ ចំពោះដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧។

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

វិសាមញ្ញក្នុងពេលដំណាក់កាលស៊ើបអង្កេត ឬមុនអង្គសេចក្តី ជាទៀតទាត់តាមពេលកំណត់ វាហាក់ដូចជាមិនអើពើទៅនឹងកិច្ចខិតខំប្រឹងប្រែងយ៉ាងខ្លាំងខ្លារបស់រាជរដ្ឋាភិបាលកម្ពុជា ជាពិសេសរបស់ **សម្តេច ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ក្នុងការនាំមកនូវសុខសន្តិភាព និងភាពសុខសាន្តជូនប្រទេសកម្ពុជា"[85]។

សហព្រះរាជអាជ្ញាអះអាងថា "ការអះអាងនៅក្នុងបណ្តឹងឧទ្ធរណ៍ដែលលើកឡើងថា តុលាការនេះគួរបង្គាប់ឱ្យដោះលែង ប្រសិនបើមានការធានាពីវត្តមានរបស់ជនត្រូវចោទ វាមិនមានភស្តុតាងគាំទ្រណាមួយទេ។ ទោះជាយ៉ាងណាក៏ដោយ **អៀង សារី** ពុំបានផ្តល់ការធានាបែបនេះទេ។ គាត់ពុំបានលើប្រភពច្បាប់ណាមួយមកសំអាងដើម្បីបង្ហាញថា នេះអាចជាហេតុផលតែមួយគត់សម្រាប់ការដោះលែង។ សូម្បីតែការធានាពីរដ្ឋក៏ដោយ ក៏តុលាការព្រហ្មទណ្ឌអន្តរជាតិជួនកាលបានធ្វើមិនដឹងមិនឮដែរ ហើយបានបង្គាប់ឱ្យឃុំខ្លួន ប្រសិនបើរកឃើញថាមានមូលហេតុពាក់ព័ន្ធ។ នៅក្នុងឧបសម្ព័ន្ធ ក នៃបណ្តឹងឧទ្ធរណ៍ ក៏បានលើមកសំអាងផងដែរនូវយុត្តិសាស្ត្រដែលមានអង្គហេតុដាច់ដោយឡែងពីគ្នា ដែលតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី បានសម្រេចអនុញ្ញាតឱ្យដោះលែងបណ្តោះអាសន្នដល់ជនជាប់ចោទរបស់ខ្លួនមួយចំនួន។ យុត្តិសាស្ត្រទាំងនេះគឺជាជំនួយតិចតួចប៉ុណ្ណោះដោយសារតែសេចក្តីសម្រេចលើការឃុំខ្លួនបណ្តោះអាសន្ន ចាំបាច់ត្រូវលើកឡើងពីកាលៈទេសៈពិសេសដោយឡែកនៃរឿងក្តីនិមួយៗ"[86]។

សហព្រះរាជអាជ្ញាបញ្ជាក់ថា "បណ្តឹងឧទ្ធរណ៍ចោទប្រកាន់ថា ប្រសិនបើហេតុផលអំពីភាពផុយស្រួយរបស់សង្គមត្រូវបានធានា នោះគ្មានចុងចោទណាម្នាក់ត្រូវបានដោះលែងឱ្យក្រៅឃុំបណ្តោះអាសន្ននោះឡើយ។ បណ្តឹងឧទ្ធរណ៍នេះបានយោងទៅសេចក្តីសម្រេចរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីដែលបានអនុញ្ញាតឱ្យមានការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យរបស់តុលាការដល់ចុងចោទមួយចំនួន ដោយគ្មានការរំខានសាធារណៈក្នុងសង្គមនៃអតីតប្រទេសយូហ្គោស្លាវីឡើយ។ សហព្រះរាជអាជ្ញាលើកឡើងថា កាលៈទេសៈពិសេសដោយឡែករបស់ អ.វ.ត.ក គួរត្រូវបានយកមកពិចារណា នៅពេលសម្រេចសេចក្តីលើបញ្ហានេះ។ ខុសពីតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ត្រង់ថាតុលាការនេះមានទីតាំងស្ថិតនៅក្នុងប្រទេសដែលជាទីកន្លែងមានការចោទប្រកាន់ថាមានការប្រព្រឹត្តិឧក្រិដ្ឋកម្ម មានភស្តុតាងនៅទីនេះ ព្រមទាំងមានចុងចោទជនរងគ្រោះ និងសាក្សីរស់នៅជាប្រក្រតីនៅទីនេះ។ ស្ថិតក្នុងកាលៈទេសៈប្រហាក់ប្រហែលគ្នានេះដែរ មកដល់

---

[85] កថាខណ្ឌទី៣៨, ៣៩ និង៤០ នៃសារណាបណ្តឹងឧទ្ធរណ៍របស់ **អៀង សារី** ចុះថ្ងៃទី ១៥ ខែ មករាឆ្នាំ ២០០៨ ចំពោះដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧។

[86] កថាខណ្ឌទី៤១ និង៤២ នៃសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី២៩ ខែ មករា ឆ្នាំ ២០០៨ ដែលឆ្លើយតបទៅនឹងសារណាបណ្តឹងឧទ្ធរណ៍របស់ **អៀង សារី** ចំពោះដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧។

E.C.C.C * C.E.T.C. * TRIAL CHAMBER CHAMBRE PRÉLIMINAIRE

ពេលនេះ តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន ពុំបានអនុញ្ញាតឲ្យមានការដោះលែងឲ្យនៅក្រៅឃុំបណ្ដោះអាសន្នឡើយ"[87]។

សហព្រះរាជអាជ្ញាលើកឡើងថា "ពុំមានយុត្តិសាស្ត្រ បទពិសោធន៍អនុវត្ត ឬសមត្ថភាពពិតប្រាកដ ដើម្បីផ្ដល់ការការពារ ឬយន្តការប្រតិបត្តិដល់ជនសង្ស័យដែលអាចត្រូវបានគេដោះលែងក្រោមការត្រួតពិនិត្យរបស់របស់តុលាការឡើយ ជាពិសេសដល់ជនដែលមានកេរ្តិ៍ឈ្មោះអាក្រក់ដូច **អៀង សារី** នេះឡើយ។ [...] សហព្រះរាជអាជ្ញាលើកឡើងថា ចុងចោទដែលទទួលការចោទប្រកាន់ថាមានពាក់ព័ន្ធយ៉ាងខ្លាំង និងយ៉ាងចម្រូងចម្រាស់ ដែលអាចមើលឃើញយ៉ាងច្បាស់ ពីបទឧក្រិដ្ឋកម្មអន្តរជាតិដ៏អាក្រក់នៅចំពោះមុខតុលាការពិសេសនេះ មិនគួរជាជនទីមួយសម្រាប់សាកល្បងប្រព័ន្ធនេះឡើយ"[88]។

សហព្រះរាជអាជ្ញាលើកឡើងបន្ថែមថា អំណះអំណាងរបស់សហមេធាវីការពារក្ដីទាក់ទងនឹងសុខភាពរបស់ **អៀង សារី** "ពុំមានអង្គហេតុណាមួយគាំទ្រឡើយ"[89]។ សហព្រះរាជអាជ្ញាលើកឡើងបន្ថែមទៀតថា "មន្ទីរឃុំឃាំងបានទទួលបានការយកចិត្តទុកដាក់ពីប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ដោយសារតែមន្ទីរឃុំឃាំងនេះមានអាគារ សម្ភារៈ និងសេវាសមស្រប"[90]។

មេធាវីរបស់ដើមបណ្ដឹងរដ្ឋប្បវេណីលើកឡើងថា "ជនត្រូវចោទទទួលបានការពិនិត្យសុខភាពយ៉ាងទៀតទាត់។ ការឃុំខ្លួន (នៅតែ) មានលក្ខណៈសមស្របមិនប៉ះពាល់ដល់ស្ថានភាពសុខភាពទេ"[91]។

ភ្នំពេញ, ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ ២០០៨

**សហចៅក្រមរបាយការណ៍**

**ចៅក្រម នៃយ ថុល** **ចៅក្រម** Katinka LAHUIS

[87] កថាខណ្ឌទី៥៥ នៃសេចក្ដីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី២៨ ខែ មករា ឆ្នាំ ២០០៨ ដែលឆ្លើយតបទៅនឹងសារណាបណ្ដឹងឧទ្ធរណ៍របស់ **អៀង សារី** ចំពោះដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧។

[88] កថាខណ្ឌទី៦២ និង៦៣ នៃសេចក្ដីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី២៨ ខែ មករា ឆ្នាំ ២០០៨ ដែលឆ្លើយតបទៅនឹងសារណាបណ្ដឹងឧទ្ធរណ៍របស់ **អៀង សារី** ចំពោះដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧។

[89] កថាខណ្ឌទី៦៥ នៃសេចក្ដីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី២៨ ខែ មករា ឆ្នាំ ២០០៨ ដែលឆ្លើយតបទៅនឹងសារណាបណ្ដឹងឧទ្ធរណ៍របស់ **អៀង សារី** ចំពោះដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧។

[90] កថាខណ្ឌទី៦៦ នៃសេចក្ដីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី២៨ ខែ មករា ឆ្នាំ ២០០៨ ដែលឆ្លើយតបទៅនឹងសារណាបណ្ដឹងឧទ្ធរណ៍របស់ **អៀង សារី** ចំពោះដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧។

[91] កថាខណ្ឌទី៤៧ នៃសារណាតបរួមរបស់សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី ២០ ខែឧសភា ឆ្នាំ ២០០៨ ដែលឆ្លើយតបទៅនឹងសារណាបណ្ដឹងឧទ្ធរណ៍របស់ **អៀង សារី** ចំពោះដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន។

E.C.C.C. * C.E.T.C. PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE